R-le 2-12-52
Cosseaneaveaddey

# ព្រះរាជាណាចក្រកម្ពុជា

## មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

# គ្រូបង្រៀន

ឆ្នាំទី ៤ លេខ ៤

ខែធ្នូ ព.ស. ២៤៩៥

ឆ្នាំសិក្សា ១៩៥២-១៩៥៣

# ព្រះរាជអាណាចក្រកម្ពុជា

## មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សំរាប់គ្រូបង្រៀន

បញ្ជី រឿង ទំព័រ


សេចក្ដីណែនាំ ... ... ... ... ... ... ... ... ... ... ... ... ... ៣

ឧត្ដមដ្ឋាន - មធ្យមដ្ឋានទី ២ ភាសា ... ... ... ... ... ... ... ... ១០

មធ្យមដ្ឋាន ទី ១ ភាសា ... ... ... ... ... ... ... ... ១៩

អាទិកដ្ឋាន ភាសា ... ... ... ... ... ... ... ... ២២

បវិច្ចណដ្ឋាន ភាសា ... ... ... ... ... ... ... ៣០

កុមារដ្ឋាន ភាសា ... ... ... ... ... ... ... ... ៣៥

តែងសេចក្ដីសម្រាប់ប្រថមភូមិបំពេញវិជ្ជា ... ... ... ... ... ៣៨

តែងសេចក្ដីសម្រាប់ប្រថមភូមិជាន់ដំបូង ... ... ... ... ... ... ៤២

អាទិកដ្ឋាន—នព្វន្ត—រង្វាស់រង្វាល់ .. .. .. .. ... .. ... ... ៤៧

បវិច្ចណដ្ឋាន—នព្វន្ត—រង្វាស់រង្វាល់ .. .. .. .. .. .. .. .. . ៥៦

កុមារដ្ឋាន—នព្វន្ត—រង្វាស់រង្វាល់ ... ... .. ... ... .. ... ៦១

អាទិកដ្ឋាន—វត្ថុស្វាធ្យាយន៍—វិធីបង្ការរោគ .. .. ... ... ... ៦៥

បវិច្ចណដ្ឋាន—វត្ថុស្វាធ្យាយន៍—វិធីបង្ការរោគ ... .. .. .. . ៧០

កុមារដ្ឋាន—វត្ថុស្វាធ្យាយន៍ វិធីបង្ការរោគ .. ... .. .. ... ... ៧៣

លោកនីតិសម្រាប់គ្រប់ថ្នាក់ ... ... ... ... .. .. .. ... .. ៧៩

មេសូត្រតែមាត់ សម្រាប់គ្រប់ថ្នាក់ .. .. .. .. .. .. .. .. ៨៩

... DOCUMENTATION & D'ÉDITION
BIBLIOTHEQUE

| Inventaire | | Date | 8·8·63 |
|---|---|---|---|
| CDU | | Côte | |

# សេចក្ដីណែនាំ

## អំពីក្បួនច្បាប់ហើយនិងរបៀបបង្រៀន(តមក)

ត្រូវនាំសិស្សគិតពិចារណា .– គ្រាន់តែចេះចោទសួរកូនសិស្សនិងគ្រាន់តែចេះនាំកូនសិស្សឲ្យឆ្លើយត្រូវនិងពាក្យចោទសួរនោះមិនទាន់ជាការពេញបរិបូណ៌ទេ ត្រូវនាំសិស្សឲ្យគិតពិចារណាផង ។

ពាក្យចោទសួរត្រូវជាកិច្ចបង្ខំកូនសិស្សឲ្យគិតនឹករកសេចក្ដីឆ្លើយ ត្រូវជាការទម្លាប់កូនសិស្សឲ្យយល់ឲ្យជ្រៅអំពីកិរិយាដែលធ្វើ ហើយនិងអំពីកិច្ចផ្សេងៗដែលមាននៅក្នុងកិរិយានោះផង ។

ដូចជាក្នុងច្បាប់ដំបូន្មានជាប្រធាន ត្រូវមានពាក្យចោទសួរច្រើន គឺដូចជាពាក្យថា អ្នកយល់ឃើញដូចម្ដេចអំពីកិរិយាដូច្នេះ ដូច្នោះ អ្នកយល់ឃើញដូចម្ដេចអំពីមនុស្សនេះ មនុស្សនោះ ។

ត្រូវឲ្យកូនសិស្សត្រិះរិះគិតរកសេចក្ដីយោបល់ក្នុងរឿងនិទាន ហើយឲ្យវាពិចារណាអំពីកិរិយាដែលគេធ្វើនោះ ឬអំពីមនុស្សនោះៗ ។ កិរិយាហើយនិងហេតុត្រូវផ្លាស់ប្ដូរទៅតាមការផ្សេងៗ ដែលក្មេងត្រូវដឹងហើយត្រូវថាតាមគំនិតវាយល់ឃើញ ហើយលោកគ្រូត្រូវណែនាំជួយឲ្យវារកផងៗ

ក្នុងសេចក្ដីខ្លះលោកគ្រូត្រូវពិភាក្សាជាមួយនិងកូនសិស្សដូចជាជំនុំជំ-

វះសេចក្ដីនៅក្នុងសាលាជុំនុំ ត្រូវពិនិត្យកិរិយាដែលគេធ្វើដូចមានក្នុងសេចក្ដីនិទាន ឬពិនិត្យកិរិយាកូនសិស្សណាម្នាក់ ប៉ុន្តែត្រូវកូនសិស្សគិតពិចារណាជាដរាបត្រូវឲ្យត្រិះរិះគិតរកសេចក្ដីយោបល់ថា ជាល្អឬជាអាក្រក់ ជាខុសឬជាត្រូវ ជាការគួរធ្វើឬពុំគួរធ្វើ ។

ត្រូវនាំសិស្សគិតពិចារណាដោយបញ្ញាស្មារតី.— កាលណាក្មេងស្ដាប់គេនិទានរឿងព្រេងវាមានគំនិតគិតទៅដល់ថាយក្សតែងតែ-នឹងធ្វើបាបគេ ភ្នែកវាធំៗមូលក្រឡោត ក្បាលវាធំកំប៉ុង ខ្លួនវាធំសម្បើម ហើយ ក្មេងដឹងថាព្រៃស្ងាត់ជ្រងំដែលជាកន្លែងយក្សវានាំយកមនុស្សនឹងសត្វទៅបរិភោគ ឬដឹងថាទន្លេជ្រៅដែលយក្សវាលោតកន្លងតែមួយផ្លោតរួចទៅ ។

ក្មេងវានឹកឃើញអំពីយក្សហើយនឹងបែបភាពទីកន្លែងដូច្នេះ ពីព្រោះវាបានឃើញគំនូររូបយក្សវាបានឃើញព្រៃដែលវាធ្លាប់ទៅបេះផ្លែឈើ ឬជីកមើមឈើយកមកអាស្រ័យ ហើយវាធ្លាប់បានឃើញទន្លេដែលវាទៅងូតទឹកនោះផង វានឹករលឹកទៅឃើញដូច្នេះ ហើយនិយាយឡើងវិញបាន ពីព្រោះវាបានឃើញ ឬបានឮគេនិយាយរួចហើយ បើចង់ឲ្យកូនសិស្សអធិប្បាយអំពីរឿងអ្វីមួយដែលមានក្នុងគ្រាឥឡូវនេះដោយគំនិតត្រូវលោកគ្រូចោទសួរវាយ៉ាងស្រួលបួល កូនសិស្សវានឹងរលឹកនឹកឃើញរឿងនោះ

មកនិយាយឡើងវិញបាន កិរិយាធ្វើយ៉ាងដូច្នេះជាកិច្ចបង្ខំសិស្សឲ្យគិតនឹករកដោយប្រាជ្ញាស្មារតីឲ្យសំគាល់ច្បាស់ប្រាកដក្នុងប្រាជ្ញាស្មារតីផង ឲ្យសំគាល់របស់ទាំងសំគាល់សេចក្តីល្អអាក្រក់ផង ប៉ុន្តែមានហេតុពុំគប្បីដែលត្រូវនឹងជៀសវាង គឺកូនសិស្សរមែងតែនិយាយបំផ្លើសហួសអំពីសេចក្តីដែលមានជាប្រាកដ ដូចកាលវានិយាយកែច្នៃក្លាយអំពីមនុស្សឬអំពីសត្វ អំពីការដែលគេធ្វើឬអំពីវត្ថុអ្វីៗដែលមិនត្រូវមានក្នុងលោកនេះសោះ ដូច្នេះលោកគ្រូត្រូវពិនិត្យមើលសេចក្តីដែលកូនសិស្សអធិប្បាយនោះ កុំឲ្យវានិយាយហួសអំពីការសុចរិត ពីព្រោះសេចក្តីដែលកូនសិស្សគិតនឹករកដោយប្រាជ្ញាស្មារតីនេះ ត្រូវឲ្យប្រកបនឹងសេចក្តីដែលមានមែននោះផង គឺការដែលមានជាធម្មតានេះហើយក្មេងត្រូវចេះចាំចំណាំយកមកអធិប្បាយមេរៀនដែលលោកគ្រូបង្រៀនត្រូវបំពេញលើសេចក្តីដែលកូនសិស្សត្រិះរិះគិតនាំយកមកប្រឌិតអធិប្បាយនោះហើយនឹងបំពេញសេចក្តីចំណាំរបស់វាផង ដូច្នេះត្រូវបណ្តុះប្រាជ្ញាស្មារតីកូនសិស្សតែពីការអ្វីដែលមានពិតប្រាកដ ៗ ធ្វើដូច្នេះកូនសិស្សនឹងចាំបន្តិចម្តង ៗ សេចក្តីដែលមានមែនប្រាកដនោះ នឹងចំណាំពាក្យហើយនឹងរឿងដែលលោកគ្រូនិទាននោះទុកជាគោលចារឹកតទៅ ក្មេងមិនគ្រាន់តែចេះពាក្យដែលបានរៀននោះទេ នឹងដឹងថាពាក្យនោះមានសេចក្តីដូច្នោះ ៗ សំរាប់ជួសរបស់នោះ ៗ ផង ៗ

ដល់កាលណាយើងអធិប្បាយសេចក្ដីណា នាំអំពីរបៀបបង្រៀនមេរៀនមួយ ៗ យើងនឹងពណ៌នាអំពីសេចក្ដីនេះទៀត ហើយនឹងពន្យល់អំពីការត្រូវធ្វើដូចម្ដេចៗ ឲ្យក្មេងសំគាល់ជាក់ច្បាស់ក្នុងប្រាជ្ញាស្មារតីវាដោយមានគំនូរមានពាក្យនិទានមានរូបជាទីតាំង ។

## ហេតុបណ្ដាលអំពីសេចក្ដីមិនប្រុងប្រយ័ត្ន

ទោះជាគ្រូប៉ិនប្រសប់ខាងទស្សដល់សិស្ស ប្រយោជន៍បង្ខំវាឲ្យធ្វើយត្រូវសេចក្ដីយ៉ាងណាក៏ដោយ ក៏គង់តែមានកូនសិស្សពាយមាយស្មារតីចេញទៅក្រៅការរៀនសូត្រមួយភ្លែត ១ ជាដរាប វាគិតតាំងទៅវាមិនស្ដាប់ទេ ពីព្រោះយើងបង្ខំឲ្យវាប្រុងប្រយ័ត្ន នេះជាការប្រាថ្នាលើវាធំណាស់ កាលណាមានរបស់អ្វី នាំប្រទៀងវាឬនាំឲ្យវាសប្បាយ ក្មេងវាមានតែចំណង់ចង់ឈប់រៀនភ្លាម ហើយគិតពាយមាយទៅការរបស់នោះ ឬល្បែងនោះ ពីព្រោះនៅក្នុងកន្លែងរៀន បើនិយាយដោយពិតទៅគ្មានអ្វីជាការសប្បាយឲ្យវាសោះ មានការនាំឲ្យវាសប្បាយដែរ ប៉ុន្ដែលោកគ្រូត្រូវពិនិត្យមើលការនោះឲ្យមែនទែន ។

ភ្នែកហើយនឹងត្រចៀកក្មេងចង់តែសប្បាយ ដោយមានគូកននៅជិតខាងចង់បែរទៅនិយាយលេង ឬមានពុស្សរូវអ្វីមួយយ៉ាង ១ ឬមានមនុស្ស

គេដើរនៅមាត់ទ្វារ ។ល។ ជួនកាលលោកគ្រូបណ្ដោយឲ្យវាមិនប្រុងប្រយ័ត្នពីព្រោះលោកគ្រូនិយាយឮតិចពេកមិនច្បាស់សេចក្ដី ឬលោកគ្រូមានសេចក្ដីដូចជាព្រួយចិត្ត ឬលោកគ្រូមិនស្មោះចំពោះនឹងការដែលលោកនិយាយ ជួនកាលទៀតលោកនិយាយញាប់ពេកណាស់ទាល់តែកូនសិស្សស្ដាប់មិនទាន់ ឬលោកគ្រូឈប់បន្ទោសក្មេងនេះក្មេងនោះច្រើនពេក ហេតុទាំងអស់នេះនាំបណ្ដាលឲ្យកូនសិស្សរាបង់ដេក ឬមានចិត្តណាយមាយពីការរៀនសូត្រទៅកាន់ទីដទៃៗ ។

បំពួកមួយទៀតមានហេតុបណ្ដាលអំពីលោកគ្រូទៅលើកូនសិស្ស ពីព្រោះលោកគ្រូចេះបង្រៀនមិនជិតដល់ ឬលោកគ្រូរៀបចំការបង្រៀនមិនល្អ មេរៀនមិនប្រកបនឹងដំរិះកូនសិស្ស បើទោះជាលោកគ្រូប៉ិនប្រសប់បង្រៀនបរិបូណ៌ហើយប្រសប់តែងមេរៀនឲ្យច្បាស់ៗងាយៗ ហើយធ្លាតក្នុងការចោទសួរពីព្រោះក្មេងចង់តែងាកទៅឯណេះទៅឯណោះ ត្រូវបំពេញសេចក្ដីចំណង់របស់វានេះឲ្យបាននៅក្នុងកន្លែងរៀនតាមរបៀបឯណាមួយហេតុដូច្នេះហើយទើបបានជាឲ្យមានពេលចេញលេង ។

ពីព្រោះបន្ទូរតាមធុរៈក្មេងដូច្នេះទៀត បានជាយើងសូមលោកគ្រូបង្ហាត់កូនសិស្សឲ្យនិយាយខ្លាំងៗព្រមគ្នា ហើយនឹងឲ្យការហាត់ព្រមគ្នានៅក្ដារខៀនតាមរបៀបផ្សេងៗផង ។

អំពីបង្ហាត់កូនសិស្សឲ្យនិយាយខ្លាំងៗព្រមគ្នា

ឯរបៀបនេះលោកគ្រូជាប់ណាស់ហើយ ពីព្រោះកាលពីដើមគេតែងតែឮក្មេងនៅវត្តស្រែកមើលសត្រាឮស្នូរស័ព្ទកងរំពង ក្មេងចូលចិត្តធ្វើដូច្នេះបានច្រើនតាមពេលវេលាផង ក៏គង់តែមានកូនសិស្សនៅបង់ធ្មៀតលេងបាន ពីព្រោះវាបង់ស្រែកខ្លាំងៗជាការលេងសប្បាយផង ធ្វើដូច្នេះក្មេងនឹងឈប់លែងបង់និយាយគ្នា ម្យ៉ាងទៀតវានឹងប្រុងប្រយ័ត្នធ្វើសំឡេងឲ្យមានរបបនឹងគ្នាផង ។

យើងត្រូវចាំថាមានមេរៀនខ្លះសេចក្ដីប្រុងប្រយ័ត្នស្ដាប់ជាការមានប្រយោជន៍ធំណាស់ ដូចជាក្នុងវិជ្ជានព្វន្ធ បើក្មេងរាប់ឬគិតលេខថាខ្លាំងៗ ក្មេងឯទៀតឮគេថាខ្លាំងនោះនឹងបានចាំចំនួនបូករួមឬដើរល័ក្តបានមិនចាំបាច់ឃើញគេសរសេរចំនួននោះទេ ។

បើត្រូវឲ្យចំណាំរៀបរាប់រាយឈ្មោះអ្វី ៗ ក្នុងសេចក្ដីណាមួយត្រូវបង្ហាត់កូនសិស្សឲ្យនិយាយខ្លាំងៗព្រមគ្នា ក៏ប៉ុន្តែត្រូវហៅសួរកូនសិស្សម្នាក់ ៗ ដើម្បីបញ្ជាក់សេចក្ដីដែលវាថានោះផង ក្នុងវិជ្ជាវ៉ាស់វ៉ាល់នឹងវិជ្ជាភូមិសាស្ត្រក៏ត្រូវបង្ហាត់ដូច្នេះដែរ ។

ម្យ៉ាងទៀតត្រូវបង្ហាត់ឲ្យថាខ្លាំង ៗ ព្រមគ្នាក្នុងវិជ្ជាសូត្រមេទន្ទេញ ប៉ុន្តែក្នុងវិជ្ជានេះត្រូវប្រយ័ត្នឲ្យវាថាច្បាស់ ៗ ប្រយោជន៍នឹងដឹងថាកូនសិស្ស

បានយល់សេចក្ដីដែលវាសូត្រនោះជាក់ប្រាកដផង ។

នឹងធ្វើឲ្យបានប្រយោជន៍នេះ ត្រូវលោកគ្រូនិយាយជាមួយនឹងកូនសិស្សៗ នឹងយកដំកប់ថាឲ្យត្រូវតាមលោកគ្រូ ។

ការបង្ហាត់កូនសិស្សឲ្យនិយាយខ្លាំងៗព្រមគ្នាជាការមានប្រយោជន៍សំខាន់ក្នុងវិធីបង្រៀនមើល ពីព្រោះបង្រៀនមើលត្រូវថាប្រកបអក្សរឲ្យកើតជាសំឡេងជាពាក្យនិយាយបានជាសេចក្ដីតាមតួអក្សរនោះៗ ប៉ុន្តែមានហេតុពុំគប្បីក្នុងការបង្រៀនមើលឲ្យថាខ្លាំងៗព្រមគ្នានេះ គឺមកអំពីបណ្ដោយឲ្យកូនសិស្ស ជាមិនមើលអក្សរ ដូច្នេះហើយបានជាមានកូនសិស្សខ្លះចាំតែមាត់ដល់ឲ្យមើលអក្សរមើលមិនដាច់ ហេតុនេះបណ្ដាលមកតែពីវាមិនចំណាំតួអក្សរ ។ បើដោះជាបង្ហាត់វិជ្ជាអ្វីៗក៏ដោយសូមលោកគ្រូកុំឲ្យក្មេងថាខ្លាំងពេកពាល់តែឡប់ក្មេងដែលនៅជិតខាងវានោះ លោកគ្រូត្រូវប្រុងប្រយ័ត្នធ្វើកុំឲ្យមានសេចក្ដីបន្ទប់ឲ្យសោះ ។

ម៉ា ឆិតពូជ

ស្រង់ពីកិច្ចសិក្សាវិជ្ជាបារាំងសែស - ខេមរ ខែ

ណោវែមប្រ៍ ១៩៣៣

ភ. ឈ.

## ឆាយល្អ

មានស្តេចព្រាបមួយនាំបរិវារទៅរកស៊ីនៅទីវាលស្រែ ទៅឃើញលប់នាយព្រានគេដាក់ នាយព្រានបាចសាចស្រូវអង្ករជានុយ ឯពួកព្រាបទាំងឡាយ ឃើញនុយដូចនោះគិតនាំគ្នានឹងចុះស៊ី ៗ ឯស្តេចព្រាបគិតថា ស្រូវអង្ករនេះជារបស់រកបានដោយក្រ នេះហេតុម្តេចក៏មនុស្សគេមកបាចសាចចោលពាយពាសដូចនេះ ទំនងជានុយបញ្ឆោតឲ្យពួកព្រាបចុះស៊ី ហើយគេនឹងរាត់ជាប់ដោយលប់នេះឯងជាប្រាកដ ៗ ស្តេចព្រាបគិតដូចនោះ ហើយទើបពោលហាមព្រាបជាបរិវារ កុំឲ្យចុះស៊ីស្រូវនោះឡើយ ៗ

ឯព្រាបជាបរិវារទាំងឡាយពុំស្តាប់ ទើបនិយាយគ្នាថា យើងស្វែងរកអាហារសព្វថ្ងៃនេះបានដោយក្រ ឥឡូវនេះមកបានឃើញអាហារល្អមបរិភោគហើយ នាយយើងមកហាមមិនឲ្យចុះយ៉ាងនេះ តើនឹងចាំទៅរកឯណាទៀតឲ្យលំបាក ៗ ស្តេចព្រាបឮដូចនោះក៏ថាអ្នកទាំងឡាយគ្មានបញ្ញា ឃើញតែអាហារក៏ហើរចុះស៊ី ពុំដឹងក្តីអន្តរាយទៅខាងមុខនឹងបានទុក្ខដល់អាត្មា ដូចពាក្យបូរាណថា: “ព្រោះបំណីត្រូវក្តីព្រើនក្លាត់” នៃអ្នកទាំងឡាយស្រូវអង្ករដែលគេពាយពាសវាលនេះ គឺជានុយដូចជាត្រីស៊ីនុយជាប់សន្ទូចគេនោះឯងហើយ បូរអ្នកទាំងឡាយកុំចុះទៅ

ស៊ីស្រូវគេនោះឡើយ ៗ ឯព្រាបទាំងឡាយពុំជឿស្ដាប់ស្ដេចព្រាបហាមឡើយ នាំគ្នាចុះទៅស៊ីស្រូវក្នុងលប់នាយព្រាន ឯស្ដេចព្រាបឃាត់បរិវារពុំស្ដាប់ដូចនោះ ក៏គិតថាបើអញមិនចុះទៅផង សមបីពួកព្រាបអស់នេះនឹងវិនាសដោយដៃមនុស្សមិនខាន កុំដូចនោះឡើយអាត្មានឹងចុះទៅផងចុះ គិតហើយស្ដេចព្រាបក៏ហើរចុះទៅក្នុងលប់នោះផង ៗ

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

ពន្យល់ពាក្យ

បរិវារ ឬបរិពារ = ន. អ្នកហែហមកំដរជាកិត្តិយស ៗ

នុយ = ន. បំណាប់បញ្ឆោតជាគ្រឿងប្រលោមទាក់ចិត្ត ៗ

អន្តរាយ = សេចក្ដីវិនាស

សូម្បី = គួរបី – គួរគប្បី

សទិសសព្ទ : ព្រាប (ន.) សត្វព្រាប ៗ

ប្រៀប (កិ.) ប្រៀបផ្ទឹម ៗ

ព្រៀប (កិ. វិ.) ពេញព្រៀប ៗ

អក្ខរាវិរុទ្ធ : បរិវារ (រ) – លប់ (ប់) – លុបលាង (លុ) អង្ករ (រ) ៗ

សួរចោទ.– ស្ដេចព្រាបឃើញលប់នឹងនុយ ហើយនិយាយប្រាប់បរិវារដូចម្ដេចខ្លះ ?

ព្រាបទាំងឡាយទទួលស្លាប់ឬទេ? ដោយហេតុអ្វី?

ការរឹងទទឹងនឹងនាយពៅហ្វាយ បានគឺដូចម្តេច?

## ឆាយល្អ (៣)

ឯនាយព្រានឃើញព្រាបចុះច្រើន ហើយក៏គ្រនាក់ខ្សែលប់នោះ មួយរំពេច ព្រាបទាំងឡាយក៏ត្រូវជាប់គេវៀបក្នុងសំណាញ់នោះជាមួង ទើបស្តេចព្រាបនិយាយថា ម្តេចអ្នកទាំងឡាយឃើញគ្រោះអន្តរាយដ៏តពិតហើយឬ? បើដូចនេះអ្នកពលគ្នាទីងគិតយ៉ាងណា ទើបរក្សាជីវិតបាន ។

ឯព្រាបទាំងឡាយនាំគ្នាទូលទោសខុសថា យើងខ្ញុំទាំងឡាយពុំដឹងគិតយ៉ាងណាទេ ទាល់ចំណោះអស់ហើយ លោកមានឧបាយយ៉ាងណាប្រោសមេត្តាដោះទុក្ខយើងខ្ញុំឲ្យរួចជីវិតផង ។

ឯស្តេចព្រាបថា: ភ័យម្តងនេះជាភ័យយ៉ាងធំបំផុតកម្រនឹងកែខ្លួនបាន ដូចនេះអ្នកឯងពលគ្នាកុំប្រមាទ ខំឧស្សាហ៍តាំងសតិឲ្យខ្ជាប់ចុះ អាស្រ័យការព្រមព្រៀងចិត្តគ្នា ខំតាំងកំឡាំងឲ្យព្រមគ្នាចុះ យើងប្រឹងស្ទុះហើរឡើងឲ្យព្រមគ្នាដើម្បីនឹងឲ្យលប់នេះដាច់ខាតបាក់ទ ។

ឯព្រាបទាំងឡាយក៏ធ្វើតាម ទើបនាំគ្នាស្ទុះហើរឡើងព្រមគ្នា ឯខ្សែ

លប់នោះក៏ដាច់ចាកទីមួយរំពេច ព្រាបទាំងឡាយក៏ហើរនាំលប់នោះឡើងទៅលើអាកាសបាន ហើយហើរទៅដល់ទីដំបូកមួយ ជាទីលំនៅនៃស្តេចកណ្តុរ កណ្តុរនោះជាសម្លាញ់នឹងស្តេចព្រាបអំពីដើមមក ថ្ងៃដែលព្រាបទាំងឡាយទៅធ្លាក់លើដំបូកនោះ ស្តេចកណ្តុរបានដឹងថាស្តេចព្រាបនូវបរិវារជាប់លប់ហើរមកធ្លាក់ដូចនោះ ក៏នាំបរិវារនៃអាត្មាពីដំបូកមកកាត់លប់នោះដាច់ដាចអស់ នាំយកព្រាបទាំងនោះចេញអំពីលប់នោះបាន ឯស្តេចព្រាបព្រមទាំងបរិវារ ក៏បានរួចចេញចាកលប់ហើយប្រាព្ធប្រាស្រ័យចរចាប្រាប់សេចក្តីសុខទុក្ខគ្នា តាំងពីដើមដល់ចប់គ្រប់ប្រការ ស្តេចព្រាបក៏សរសើរគុណនៃស្តេចកណ្តុរ ជាកល្យាណមិត្រផ្សេង ៗ ហើយក៏លាគ្នាទៅកាន់ទីលំនៅទីទៃ ៗ ។

ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

(ស្រង់ពីសេចក្តីសំរាំងលោក ប. ឈុំ)

ពន្យល់ពាក្យ

ឧបាយ = (ម. ថា. អ៊ុបាយ) ន. ល្បិច

ប្រមាទ = ភ្លេចស្មារតី - ប្រហែស — មើលងាយ

សតិ = ស្មារតី - គំនិត

ប្រារព្ធ ឬ ប្រារភ= កិ. តាំងផ្ដើម - ផ្គងជាមុន

ប្រាស្រ័យ= ទីពំនាក់ - ទីជ្រកកោន, សន្ទនាគ្នា, ការរាក់ទាក់រកគ្នា ។

កល្យាណមិត្រ = មិត្រដ៏ប្រសើរគួររាប់អាន

អក្ខរាវិរុទ្ធ: ភ័យ (័) - ប្រមាទ (ទ) - ឧស្សាហ៍ (ហ៍) - ស្មុះ (ះ) ប្រារព្ធ (ព្ធ) ។

សួរទេ.- លុះព្រាបតាំងឡាយ ជាប់លប់ហើយស្ដេចព្រាបពោលដូចម្ដេច ?

ព្រាបបរិវារតបវិញយ៉ាងណា ? ស្ដេចព្រាបឲ្យដំបូន្មាន ហើយបង្គាប់ព្រាបជាបរិវារដូចម្ដេចខ្លះ ?

⁙

## ជំនឿរបស់អនាម័យ

ជីវិតមនុស្សយើងជារបស់ប្រសើរបំផុត បន្ទាប់មកគឺអនាម័យឬសេចក្ដីសុខសប្បាយគ្មានជម្ងឺដំកាត់បៀតបៀនរាងកាយ ប្រសិនបើយើងមានរោគប្រចាំរាងកាយជានិច្ច ទុកជាមានទ្រព្យធនច្រើនក៏មិនអាចជួយឲ្យបានសេចក្ដីសុខកាយសប្បាយចិត្តដែរ ជាជីវិតឥតប្រយោជន៍ប្រាសចាកសេចក្ដីរីករាយត្រេកត្រអាលក្នុងលោកនេះ ។

សូមឲ្យពិនិត្យមើលមនុស្សដែលមានជម្ងឺប្រចាំនៅក្នុងរាងកាយ ជានិច្ចចុះ មិនមែនរងទុក្ខវេទនាត្រឹមតែខ្លួនម្នាក់ឯងប៉ុណ្ណោះទេ អ្នកដទៃដែលឥតជម្ងឺសោះ ក៏តោងតែលះបង់ការងារមកនៅចាំថែទាំជម្ងឺខ្លួនថែមទៀត នាំឲ្យខូចខាតទាំងប្រយោជន៍ខ្លួនទាំងប្រយោជន៍អ្នកដទៃ ព្រោះតែជម្ងឺដំកាត់ដែលកើតឡើងក្នុងខ្លួនយើងនេះ ។

មនុស្សដែលកើតរោគដោយច្រើន រមែងនាំជម្ងឺដំកាត់ទៅចម្លងដល់អ្នកដទៃដែលឥតរោគក្នុងខណៈដែលខ្លួនទៅជិតគេ ឬគេចូលមកជិតខ្លួន ព្រោះជម្ងឺដំកាត់ស្ទើរតែគ្រប់យ៉ាង ដែលឆ្លងពីម្នាក់ទៅម្នាក់ទៀតនោះ ដោយងាយណាស់ ៗ តាមពិតជម្ងឺឆ្លងនេះរមែងចេញពីផ្ទះមួយទៅផ្ទះមួយ ពីភូមិមួយទៅភូមិមួយ ហើយជីវិតរបស់មនុស្សយើងតែងបាត់បង់សាបសូន្យទៅជាចំនួនច្រើនដោយអំណាចជម្ងឺឆ្លងនេះ ។

កិច្ចសំខាន់សម្រាប់មនុស្សយើងគឺការខំខ្នះខ្នែងក្នុងការរក្សារាងកាយរបស់ខ្លួនឲ្យមាំមួនល្អ ត្រូវប្រតិបត្តិតាមក្បួនវិធីបង្ការរោគ ។

ទេ មររង្សី

(ស្រង់ពីសេចក្ដីសំរាំងលោក ប-ឈុំ)

## ពន្យល់ពាក្យ

អនាម័យ = (ម.ថា អនាម៉ៃ) = ដំណើរមិនមានរោគ (សេចក្ដីសុខសប្បាយ)

វេទនា = ការទទួលអារម្មណ៍ជាទុក្ខ (តាមសេចក្ដីនិយមប្រើរបស់ខ្មែរ)

សាបសូន្យ = វិនាសអស់ – បាត់សូន្យ....

សទិសសព្ទ: = ខាន់ ឬ ខ័ន ន.ព្រះខាន់រាជ្យ ។ ខណ្ឌ (ន.) ខណ្ឌជញ្ជាំង ស្វាយខណ្ឌស្ករ ។ ខន្ធ (ន.) រំលត់ខន្ធ – ខន្ធ ៥ ។

សូន (កិ.) សូនរូបក្រមួន – សូនគុលិកា ។

សូន្យ (គ.) សូន្យសុង ស្ងាត់សូន្យឈឹង – លេខសូន្យ ។

អក្ខរាវិរុទ្ធ: ប្រសើរ (រ) - ទ្រព្យ (ព្យ) – ពិនិត្យ (ត្យ) – ទុក្ខ (ក្ខ) ស្មើរ (រ) សូន្យ - (ន្យ)

សួរចាទ – អ្វីដែលប្រសើរបំផុតនៅរាងកាយមនុស្សយើង? យ៉ាងដូចម្ដេចដែលហៅថាជីវិតឥតប្រយោជន៍? មនុស្សដែលមានរោគជានិច្ចនោះ មានសេចក្ដីវេទនាដូចម្ដេចខ្លះ? ត្រូវប្រព្រឹត្តយ៉ាងដូចម្ដេចទើបបានជៀសវាងរោគទាំងឡាយបាន?

# ខួរក្បាល

ខួរក្បាលជាសាច់ទន់ខ្ទន់ល្វន់ល្វៃប្រហែលនឹងសាច់ទូរេនយ៉ា៎ ធំមានទំហំតូចជាងក្បាលរបស់ម្ចាស់ខ្លួនបន្តិច មានទម្ងន់ប្រមាណមួយពាន់ប្រាំ-រយក្រាម ។ ឯខ្នាតខួរក្បាលធំឬតូចមានទម្ងន់ធ្ងន់ឬស្រាលមិនមែនជា-គ្រឿងវាស់សេចក្ដីល្ងង់ខ្លៅឬឆ្លៀវឆ្លាតទេ ព្រោះមនុស្សមានក្បាលធំមានខួរច្រើនតែជាមនុស្សល្ងង់ខ្លៅក៏មានគគោក ឯសេចក្ដីល្ងង់ឆ្លាត នៅត្រង់សាច់របស់ខួរក្បាលដែលមានសណ្ឋានល្អ ឬអាក្រក់មកអំពីកំណើត ហេតុនេះទើបឃើញថាខួរក្បាលល្អ មានទំនងដូចសំពត់សាច់ម៉ដ្ឋល្អ ច្រើជាប់បានយូរគង្វង់ ។ ឯខួរក្បាលអាក្រក់ប្រៀបដូចសំពត់សាច់អាក្រក់ច្រើមិនជាប់ឆាប់ហែកធ្លុះធ្លាយខូចខាតទៅវិញ ។ ខួរក្បាលនេះជាអវយវៈសំខាន់បំផុតរបស់រាងកាយ ជាអធិបតីស្ដីការលើសរសៃទាំងពួងក្នុងរូបកាយ មានទំនងដូចសេនាបតីស្ដីការក្នុងក្រសួងនិមួយៗដូច្នោះដែរ ប្រ-សិនបើខួរក្បាលពិការទៅឬអធិបតីនោះស្ដីការមិនត្រឹមត្រូវ ប្រើអំណាចរំលោភលើច្បាប់ មុខជាការងារទាំងពួងនឹងកើតវិវាទផ្ដេសផ្ដាសទៅតាមគ្នាទាំងអស់មិនខាន ។

ទេ មរង្សី

(ស្រង់ពីសេចក្ដីសំពាំងលោក ច-ឈុំ)

## ពន្យល់ពាក្យ

ខួរ = ន. អាការនៅក្នុងក្បាលឬក្នុងឆ្អឹងខាប់ដូចចាហួយ ។

សណ្ឋាន = ន. ទ្រង់ទ្រាយ - ភាព

សរីរយន្ត = (មថ. សៈរ៉ីរៈយន់) = សរីរ; - រូបរាងកាយ ។

សរីរយន្ត = យន្តគឺសរីរៈ - សរីរកាយដែលទុកដូចជាយន្ត ។

ពិការ = ន. ដែលខូចអវយវៈណាមួយប្រើការមិនកើត ។

សណ្ឋានពាក្យ = កំណើត - កើត បង្កើត ។

សទិសសព្ទ: រាង (កិ) = រាងចាល ។ រាង (ន) = រាងរល ។ រៀង (កិ. ឬ កិវិ.) = រៀងលេខ - ឈររៀងគ្នា ។ រៀង (គុ.) = លេខរៀង ។

អក្ខរាវិរុទ្ធ: ខួរ (រ) - ប្រមាណ (ណ) - ម៉ង្ឋ ឬ ម៉ង្ដ (ង្ឋ - ង្ដ) យូរ (រ) ររ (រ) ។

សួរចោទ - ខួរក្បាលយ៉ាងដូចម្ដេច ? មានទម្ងន់ប្រហែលប៉ុន្មានគីឡូក្រាម? ឯមនុស្សល្ងង់ - ឆ្លាតមកពីខួរក្បាលធំតូចឬយ៉ាងដូចម្ដេចវិញ? ខួរក្បាលល្អប្រៀបដូចអ្វី ? អវយវៈណាដែលសំខាន់ជាងគេក្នុងរាងកាយ ពីព្រោះអ្វី ?

## មជ្ឈមដ្ឋានទី ១

## បង្រៀនមើល-បង្រៀនពាក្យ

### ពាក្យទំនៀមថា

### ត្រីស៊ីក៏រួច ទន្សាយក៏រួច

មានរឿងមួយនិទានថា ៖ កាលនោះមានបុរសម្នាក់ដាក់អន្ទាក់ជាប់បានទន្សាយមួយ ទន្សាយនោះពុតធ្វើជាស្លាប់ ៗ បុរសដឹងពុតទន្សាយក៏យកវាទៅក្រុងក្នុងអង្រុតជាប់ ៗ គាត់ជួនថ្ងៃនោះ បានត្រីស៊ីមួយយកព្រោះទុកក្នុងថ្នាំង ដាក់ប្រៀបអង្រុតដែលក្រុងទន្សាយនុះដែរ ៗ បុរសចង់ល្បងយាមលោកគ្រូមើល ក៏ទៅរកលោកគ្រូចាប់យាម ដល់ហើយក្រាបថ្វាយបង្គំលោកគ្រូរួចទូលថា ៖ ព្រះតេជព្រះគុណ ក្នុងវេលាព្រឹកនេះខ្ញុំព្រះករុណានឹងមានលាភបានអ្វីទទួលទានឬទេ ?

លោកគ្រូចាប់យាមហើយឆ្លើយប្រាប់ថា "ថ្ងៃនេះបាសកឯងគ្មានលាភបានវត្ថុអ្វីបុកស៊ីទេ ស៊ីតែបាយនឹងអំបិល" ៗ

បុរសនោះញញឹមគិតថា យាមលោកគ្រូមិនពុតទេ អញមិនប្រគេន

សម្លាប់ទន្សាយនឹងត្រីស្ងោរត្រីស៊ីឆាន់ទេ ហើយក៏ថ្វាយបង្គំលាលោកគ្រូត្រឡប់ទៅផ្ទះវិញ ។

បុរសប្រើប្រពន្ធឲ្យដណ្តាំបាយ ហើយឯខ្លួនឯងយកត្រីស៊ីទៅស្រកានៅប្របមាត់ត្រពាំងនាមុខផ្ទះ ត្រីលោតផ្លោតរួចចុះទៅក្នុងទឹក ។ បុរសនោះស្រែកហៅប្រពន្ធឲ្យយកអង្រុតមកឲ្យជាប្រញាប់ ប្រពន្ធភ្លេចគិតដល់ទន្សាយក៏ស្ទុះទៅយកអង្រុតឲ្យប្តី នោះទន្សាយក៏បោលរួចទៅ ។ ប្តីនឹងប្រពន្ធឃើញទន្សាយបោលរួចដូច្នោះ ក៏រត់ដេញតាមទន្សាយតាមមិនទាន់ ទន្សាយរត់បាត់ទៅ ត្រឡប់មករកត្រី ៗ ក៏ហែលបាត់ទៅដែរ ។ បុរសប្តីប្រពន្ធមានសេចក្តីទោមនស្សដោយខាតបាតលាភដូច្នេះ ក៏ពោលពាក្យថា " ឃើយាមលោកគ្រូអញធុតណាស់តើ " ។

ពន្យល់ពាក្យ.–

ចំនៀម= បវេណី; សណ្តាប់, សណ្តាប់ធ្នាប់ ។

អន្លាក់= ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្តៅជាដើម មានក្រវិលរួតបានសម្រាប់ទាក់ សម្រាប់ដាក់ឲ្យជាប់សត្វទ្វេបាទចតុប្បាទជាដើម ។

ទន្សាយ= ( អ.ថ.ទន់សាយ ) ឈ្មោះសត្វបួនជើងប្រូនមិនផឹកទឹក ផឹកតែសន្សើម ។

ពុត= កិច្ចកលមាយា ។

អង្រុត= (អ.ថ.អង់រុត) នេសាទុបករណ៍មួយបែប ធ្វើដោយបន្ទោះឫស្សីមូល ៗ មានរាងក្រឡូម តូចខាងមាត់លើ ធំគាយខាងក្រោម សម្រាប់តុឬក្រុងមច្ឆជាតិ ។

ចាប់យាម= សង្កេតពេលយាមតាមក្បួនតម្រាហើយទាយ ។

ព្រះតេជព្រះគុណ= (អ.ថ. ព្រះតេជព្រះគុណ) គុណនៃអំណាចដ៏ប្រសើរលើសលន់ឬអំណាចនិងគុណដ៏ប្រសើរខ្ពង់ខ្ពស់ ។

ចាសក= (អ.ថ.ចាសក់) គ្រហស្ថ: ពាក្យដើមជាខចាសក គេកាត់តួ "ខ" ចេញ ពួកចាបកដើមវត្ត ។

ហាត់ភាសា= រឿងនេះគេនិយាយអំពីអ្វី? បុរសម្នាក់ដាក់អន្ទាក់ជាប់បានអ្វី? ទន្សាយនោះយ៉ាងដូចម្ដេច? ហេតុម្ដេចបានជាបុរសនោះយកទន្សាយនោះទៅក្រុងនិងអង្រុត ? បុរសនោះមានបានអ្វីដែរក្នុងថ្ងៃនោះ ? យកត្រីរ៉ស់នោះទៅទុកក្នុងទីណា ? ព្រោះអ្វីបានជាបុរសនោះទៅរកលោកគ្រូចាប់យាម ? លោកគ្រូទាយដូចម្ដេច ? បុរសនោះគិតថាដូចម្ដេច ? បុរសនោះត្រឡប់មកផ្ទះវិញរួចធ្វើដូចម្ដេច ? បុរសនោះបានសម្រេចប្រយោជន៍ដូចបំណងឬទេ ? ព្រោះហេតុអ្វី ?........។ល។

អាទិកដ្ឋាន

## បង្រៀនពាក្យហាត់ភាសា

អាទិត្យទី១.— **អំពីភូមិ**

នាម= ភូមិ ឃុំ ស្រុក ខេត្ត សាលាឃុំ មេឃុំ ផ្លូវ ផ្លូវថ្នល់ ផ្លូវជើង របង ទ្រុង ក្រោលគោ ក្របី រដូវវស្សា រដូវប្រាំង រដូវរំហើយ ៗ

គុណនាម= ទូលាយ ចង្អៀត ពិបាក ងាយ ស្រួល ខ្ពស់ ទាបៗ

កិរិយាសព្ទ= កភូមិ សង់ផ្ទះ ដើរកាត់ភូមិ ចុះពីផ្លូវធំ ឡើងមកផ្លូវធំធ្វើរបង ៗ

ហាត់និយាយ= អ្នកនៅភូមិណា ? ភូមិនោះធំឬតូច? មានផ្ទះប្រ-ហែលប៉ុន្មាន? សាលាឃុំនៅត្រង់ណា ? អ្នកដែលទៅសាលាឃុំឬទេ ? គេទៅសាលាឃុំដើម្បីអ្វី ? នៅភូមិអ្នកមានផ្លូវថ្នល់ឬទេ ? មានផ្លូវជើងប៉ុន្មាន? មកសាលារៀនអ្នកដើរតាមផ្លូវណា ? នៅជុំវិញភូមិអ្នកមានរបងឬទេ ? ព្រោះអ្វី ? ក្នុងរដូវវស្សាទឹកលិចឬទេ ? ព្រោះអ្វីបានជាទឹកមិនលិច? ហេតុអ្វីបានជាមានភូមិខ្លះទឹកលិច? អ្នកស្រឡាញ់ភូមិឬទេ? ព្រោះអ្វី?

## បង្រៀនមើល

### ភូមិខ្ញុំ

(សៀវភៅវិជ្ជាខេមរភាសាបរិច្ឆណដ្ឋាន ទំព័រ ១២)

ពន្យល់ពាក្យ — ភូមិ = ទីដែលមានប្រជុំផ្ទះលំនៅក្នុងតំបន់និមួយៗ ។

ក្រាង គឺ គ្របដោយប្រដាប់មានអង្រុតជាដើម ហើយសង្កត់ទប់ទុក "ក្រុងមាន់ឬក្រុងត្រី" ។

ក្រុង = (ច្រើនគានថាក្រុង) ន. នគរ — រាជធានី — បុរី "ក្រុងប៉ារីស — ក្រុងព្រៃនគរ — ក្រុងភ្នំពេញ" ។

ថ្លុក = ទីដីក្រហូងដែលដក់ទឹកក្នុងរដូវវស្សា ប៉ុន្តែតូចជាងត្រពាំងៗ

ត្លុក = អ្នកក្រមាប, អ្នកកំប្លែងក្នុងល្បែងរបាំដើម្បីឲ្យគេសើច ។

## សរសេរតាមសូត្រ

### អំពីភូមិខ្ញុំ

សៀវភៅដដែលទំព័រ ១២ តាំងពីភូមិខ្ញុំនៅជិតក្រុង......រហូតដល់

ពិបាកដើរទៅភូមិឬឡើងមកផ្លូវធំ ។

អក្ខរាវិរុទ្ធ— ផ្លូវកាត់ភូមិ ក្រាលថ្ម ដើរ ផ្លូវវស្សា ដក់ទឹក ភក់ ។

## តែងសេចក្ដី

ចូរបំពេញឃ្លានៅកន្លែងចន្លោះខាងក្រោមនេះ ៖

ភូមិខ្ញុំនៅជិត..........ដែលមកពីភ្នំពេញទៅឯ..........។ នៅក្នុង..........មានផ្ទះ..........ផ្ទះទាំងនោះ.......ខ្ពស់ពីដីហើយមាន..........ព័ទ្ធជុំវិញ ។ កាលណាភ្លៀងផ្លូវទាំងប៉ុន្មានក្នុងភូមិ.........ដើរ ___ ណាស់ព្រោះផ្លូវទាំងនោះមាន..........ច្រើន

## អក្សរផ្ចង់

ប ប ម ហ ប

ប បាបី បូ បុ បើ បៃ បៃ បោ បៅ បំ បាំ ភូមិបោមបៅ កុំបបេស

បបើងបង់លាភ

អាទិត្យទី២ —

# អំពីផ្សារ

នាម— ផ្សារ ផ្លូវរទេះឡាន សសរ ឥដ្ឋ បាយអ ដំបូល ក្បឿង ជញ្ជាំង ល្វែង អ្នកលក់ អ្នកទិញ ត្រី សាច់ បន្លែ ផ្លែឈើ ចេក ស្វាយ ម្នាស់ ។

គុណនាម— ធំ ទូលាយ ចំហ បិទជិត ស្រស់ ក្រៀម ឆាប់រស់ ។

កិរិយាសព្ទ— ទៅផ្សារ មកពីផ្សារ លក់ទំនិញ ជជែកគ្នា តថ្លៃទំនិញ ឈ្លោះគ្នា ជេរគ្នា ។

ហាត់និយាយ - នៅជិតភូមិអ្នកមានផ្សារឬទេ ? ផ្សារនោះយ៉ាងដូចម្តេច ? ដំបូលប្រក់អ្វី ? មានបញ្ជាំងឬទេ ? បណ្តោយនិងទទឹងផ្សារប្រវែងប្រហែលប៉ុន្មានម៉ែត្រ ? នៅក្នុងផ្សារចែកជាប៉ុន្មានល្វែង ? នៅល្វែងនីមួយមានលក់អ្វីខ្លះ ? គេលក់ត្រីនៅកន្លែងណា ? ជនជាតិណាលក់សាច់ជ្រូក ? មានលក់អ្វីទៀត ? នៅក្នុងផ្សារមានឮសូរយ៉ាងដូចម្តេច ? ផ្សារនោះធុំក្លិនយ៉ាងណា ? មានគេបោសលាងរាល់ថ្ងៃឬទេ ? អ្នកចូលចិត្តទៅផ្សារឬទេ ? ហេតុអ្វី ? ។

បង្រៀនមើល

# ផ្ការនៅភូមិខ្ញុំ

*( សៀវភៅវិជ្ជាខេមរភាសាកុមារដ្ឋានទំព័រ ១០៩ មេរៀនទី ១០ )*

## សរសេរតាមសូត្រ

*សូមយកសេចក្ដីខាងលើនេះ មកឲ្យសិស្សសរសេរតាមសូត្រផងៗ ( ធ្វើដូចរបៀបមុន ) ។*

## អក្សរផ្ចង់

ប ឞ ម ហ ឋ ឡ

បំប៉ុ បំហ៊ា បំបាក់ បំបប បំបៃរ បំអិត

បបរ ម៉ឹះៗ កែះឆ្នាំងបាយផ្ទះ ។

## បង្រៀនពាក្យបាត់ភាសា

អាទិត្យទី ៣.– សេក្ដីស្រណោះដល់ស្រុកកំណើតរបស់ខ្លួន

*( សៀវភៅវិជ្ជាខេមរភាសាបរិវច្ឆណដ្ឋានទំព័រ ៣៦ ) ។*

នាម – ស្រុកកំណើត ប្រទេស គុម្ពឫស្សី ជ្រុងស្លួន ផ្លូវតូច ។

គុណនាម.– យូរអង្វែង ដទៃ ល្អប្លែក ... ។

កិរិយាសព្ទ.– ចេញពីស្រុកកំណើត ត្រឡប់មកស្រុកកំណើត មកជុំ សួរសុខទុក្ខ ស្រណោះអាឡោះអាល័យ ។

ហាត់ភាសា.– ក្នុងរឿងនេះគេនិយាយពីអ្វី? ហេតុអ្វីបានជាបុរសនោះដើរចេញពីស្រុកកំណើត? ដល់បុរសនោះមកវិញពួកមិត្តសំ-ឡាញ់ធ្វើដូចម្ដេចខ្លះ? កាលដែលបុរសនោះដើរទេសបានឃើញអ្វីខ្លះ? បុរសនោះអាឡោះអាល័យប្រទេសដែលល្អប្លែកឬទេ? ព្រោះអ្វីបានជាបុរសនោះត្រឡប់មកជាអាឡោះអាល័យផ្ទះឪពុកម្ដាយវិញ? ផ្ទះនោះបែបភាពដូចម្ដេច? មានដាំដើមព្រឹក្សាអ្វីខ្លះព័ទ្ធជុំវិញ ?

## ២– កាំបិតបុហារនៅវត្តភូមិបាក់ខ្នារ

នាម·– ខែត្រពោធិ៍សាត់ ពេជ្ឈ ភ្នំក្រវាញ ទូកញ្ចក់ រូបទេព-ប្រណម្យ ប្រផ្នូល ហេតុ ។

គុណនាម.– បុរាណ ចំឡើប ស្អាត កខ្វក់ អត់ឃ្លាន សំបូណ៌ ។

កិរិយាសព្ទ.– ផ្លាស់ប្ដូរ ហូតកាំបិតពីស្រោម ប្រជុំធ្វើបុណ្យ ផ្សងមើលប្រផ្នូល កែហេតុ ។

ហាត់ភាសា·— វត្តភូមិបាក់ខ្នារនៅខេត្តណា ? នៅក្នុងវត្តនោះ មានរបស់អ្វីប្លែក ? ពាងថ្មនោះយ៉ាងណា ? នៅក្នុងពាងនោះមានអ្វី ? កាំបិតនោះរបស់អ្នកណា ? ទ្រង់ទ្រាយកាំបិតនោះយ៉ាងដូចម្ដេច ? បើគេផ្លាស់ប្ដូរទីកន្លែងកាំបិតនោះ តើនឹងមានហេតុអ្វី ? គេធ្វើបុណ្យផ្សងមើលប្រផ្នូលកាំបិតនោះនៅខែណា - ថ្ងៃណា ? អ្នកណាដែលត្រូវហូតកាំបិតនោះចេញពីស្រោម ? គេឃើញអ្វីនៅកាំបិតនោះ បានទំនាយថាល្អ-ទំនាយថាអាក្រក់ ? ។

## សរសេរតាមសូត្រ

សុំឲ្យជ្រើសរើសសេចក្ដីខាងលើនេះ មកដាក់ឲ្យសិស្សសរសេរតាមគ្រូជាផង ។

## អក្សរផ្ចង់

ប ប ម បិ ហ ឡ

មេមុំមូរបារី មីងម៉ែនហាំអី កុំកំហែងគេ

# តែងសេចក្ដី

## ១- អំពីភូមិ

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

អ្នកនៅភូមិអ្វី? ភូមិនោះធំឬតូច? ទទឹងនឹងបណ្ដោយមានប្រវែងប្រហែលប៉ុន្មាន? មានផ្ទះចំនួនប៉ុន្មាន? នៅជុំវិញភូមិនោះមានរបងឬទេ? នៅរដូវវស្សាភូមិនោះលិចទឹកឬទេ? នៅក្នុងភូមិនោះមានដើមឈើស៊ីផ្លែអ្វីខ្លះ? អ្នកស្រឡាញ់ភូមិអ្នកឬទេ? ព្រោះអ្វី?

## ២- អំពីផ្សារនៅភូមិអ្នក

ថ្ងៃមួយអ្នកជូនម្ដាយអ្នកទៅផ្សារ ចូរអ្នកនិយាយរាប់រៀបអំពីដំណើរនោះ តាមរបៀបខាងក្រោមនេះ ៖

១- សេចក្ដីផ្ដើម ។ ២- ពេលវេលាដែលចេញដំណើរទៅ ។ ៣- ទៅតាមផ្លូវ ។ ៤- ដល់ទៅទីផ្សារអ្នកឃើញ - ឮអ្វីខ្លះ? ។ ៥- ម្ដាយអ្នកទិញអ្វីខ្លះ? ។ ៦- អ្នកសប្បាយចិត្តឬទេ? ហេតុអ្វី ?

អាទិត្យទី ៤.—

សុំឲ្យសួរសាបជ្រៀនគ្រប់វិជ្ជាទាំងអស់តាំងពីអាទិត្យទី១ ឡើងវិញ។

បរិច្ឆណាដ្ឋាន

## រៀនពាក្យហាត់ភាសា

### អាទិត្យទី ១— ក្រុង

នាម: ទីប្រជុំជំ-ក្រុង-មន្ទីររាជការ-ផ្លូវធ្លា-បរិវេណ-ផ្សារ ។

គុណនាម. កុះករ - ស្អាត - ស្កុកស្កម - ត្រង់ទូលាយ - ឈ្ងួងរ ។

កិរិយា: ដើរលេង - ធ្វើបរ - ជិះយាន ។

ភាសា: ទីប្រជុំជំនៃស្រុកខ្មែរមានឈ្មោះហៅអ្វី ? ភ្នំពេញជាអ្វី ? ក្រុងនឹងភូមិមានសេចក្ដីប្លែកគ្នាយ៉ាងដូចម្ដេច ? អ្នកឃើញផ្ទះក្នុងក្រុងយ៉ាងដូចម្ដេច ? ផ្លូវយ៉ាងដូចម្ដេច ? មនុស្សក្នុងទីក្រុងធ្វើការរកស៊ីដូចអ្នកស្រែដែរឬអ្វី ?

ពាក្យរៀន.- នាម: ហាងជំនួញ - អ្នកជំនួញ - ឈ្មួញ - ទំនិញ - អ្នកលក់ដូរ-អ្នករាជការ - រោងល្ខោន - ភ្លើង - ប្រាសាទ - វត្ត-ផ្សារ - សួនច្បារ ឃ្លាំងទំនិញ - ផ្ទះបង់ការប្រាក់-សាលារៀន - រោងទាហាន - យានជំនិះ - ពន្លឺអគ្គិសនី - ម៉ាស៊ីនទឹក - រោងជាង - កម្មករ - (ពួកអ្នកធ្វើជាងឬគូលី)

គុណនាម: វែងវែង-កកកុញ - ខ្ពស់ត្រដែត - ធេងធាយ - ខ្វល់ - ក្រោង

ព្រាត.ត្រង់ - ទូលាយ ស្អាត - រុងរឿង ។

កិរិយា : ជួញ - ដើរលេង - បញ្ជូន - ដឹក - លក់ - ទិញ · តថ្លៃ ។

អាទិត្យទី ២.- ជំនួញ

នាម.- ហាងទំនិញ - ឃ្លាំងទំនិញ - ហាងម្ហូប · ហាងដេរស្បែក-ជើង - ហាងទឹកអប់ - ហាងប្រទីប - ហាងគ្រឿងចក្រ - ហាងគ្រឿងការី-ហាងក្រដាស ឃ្លាំងអង្ករ - ឃ្លាំងប្រេង - ឃ្លាំងលោហធាតុ - ឃ្លាំងស្រូវ-រោងពុម្ព - រោងយន្ដរោងជាង ។ អ្នកជំនួញ - អ្នកទទួលម៉ៅ - អ្នកទិញ-ថៅកែមេហាង - កូនឈ្នួល - កញ្ចក់-ហិប - ឡាំង ។

គុណនាម.- ល្អ-ប្រសើរ - អ៊ូអរ - រីមរ៉ម - ព្រោងព្រាត - ថ្មី - ចាស់ - ថ្លៃ - ថោក - គ្រឹកគ្រាក់

កិរិយា.- ទិញលក់ - តថ្លៃ - កាត់ថ្លៃ - ឡើងថ្លៃ - ជញ្ជូន - ដឹកនាំ - បញ្ជូន - រៀបគរ - លី - សែង - អូស - កណ្ដៀក - ទូល-រែក ។

អាទិត្យទី ៣ និងទី ៤.- យានជំនិះ

នាម.- រថ - រទេះសេះ - រទេះគោ - រទេះឡាន (រថយន្ត-រថសងម៉ា (រថសេះពីរ) ត្រីចក្រ (កង់បី) ទោចក្រ (កង់ពីរ) រថទូ)

រថផ្ទឹតកង់ពីរម៉ូតូស៊ីក្លូ . កប៉ាល់ - កាណូត - ទូកដរ ទូកចែវ - ទូកប៉ុកចាយ - ទូកនៃហោ - យន្តហោះម៉ាស៊ីន-កំពង់ផែ ស្ពាន-កប៉ាល់ ។

គុណនាម.— លឿន - រហ័ស - ប្រូងប្រាង - ស្អកស្កាស - ត្រៀបត្រាបត្រឹង ។

កិរិយា.— បររេះ - ឡើងចុះ - ផ្ទុក - បើក - បត - ចេញ - ចូល - ត្រួតត្រា - បំឡងវែរ - អុំ - ហោ ។

អាទិត្យទី ១.—

១ - ព្រះវិហារព្រះកែវ (បរិវច្ឆណដ្ឋាន) ទំព័រ ១០៩ - ១១០

អានពាក្យ.— មរកត (មរកត់) ពន្រាយ (ពណ្ណរាយ) ដំណើរ - ពេជ្របល្ល័ង្ក ( ប៉ាល់ឡាំង ) ។

ពាក្យខុសត្រូវគ្នា.- ព្រះវិហារ-កុំពែងរាំង-ត្បូងពណ្ណរាយ-ថ្ម-ដំណើរ១ រំពេច-សផ្ទារ-ពេជ្រ រតនបល្ល័ង្ក ។

ពាក្យពន្យល់និងពាក្យសួរ.— សូមឲ្យមើលក្នុងសៀវភៅចុះ ។

២.— ជីតាខ្ញុំ ( សៀវភៅដដែលទំព័រ ១៥ )

៣.— ជីដូនខឹងនឹងចៅ ( សៀវភៅដដែលទំព័រ ១៦ )

ពាក្យត្រូវគ្នា .- ដោយសារ—វល្លិ-ចៅអើយ—និត្យនៅ ។

អាទិត្យទី២.– ១ ត្រូវមានគួរសមដល់មនុស្សពិការ (ទំព័រ ២៩)

សុំឲ្យកែដំរូវ–គួរសម–អាទិត្យ–កិរិយា ៗ

២ – សេចក្ដីគោតខ្ជាបចាស់ព្រឹទ្ធាចារ្យ (ទំព័រ ៥៥) សុំឲ្យកែ

ដំរូវ–ព្រឹទ្ធាចារ្យ ពិសា ៗ

ស័ព្ទពាក្យ.– ចាស់ព្រឹទ្ធាចារ្យគឺចាស់ដែលគេតែងគោរព

អាទិត្យទី ៣ ទី៤.–

១.– ចូរកុំអកឡកឡើយឲ្យមនុស្សពិការ (ធម្មក្រិត្យាទំព័រ ៥៤)

២.– សេចក្ដីប្រព្រឹត្តនឹងដីតាដីដូន (ធម្មក្រិត្យាទំព័រ ១៩)

សុំឲ្យកែពាក្យ.– សេចក្ដីប្រព្រឹត្តិ (នាម) ប្រព្រឹត្ត (កិរិយា) នឹងទឹក ៗ

៣.– ដីដូនសប្បាយចិត្តនឹងចៅប្រតិបត្តិ (ធម្មក្រិត្យាទំព័រ ២១)

សុំឲ្យកែពាក្យ.– ប្រតិបត្តិ ឬ បដិបត្តិពាក្យ ៗ

បង្រៀនតាមរបៀបបានក្នុងទស្សនាវដ្ដីលេខ ១

## តែងសេចក្ដី

១.– ចូរតែងប្រយោគមួយ ជាមួយនឹងពាក្យនិមួយៗ ដូចមានខាង

ក្រោម ក្រុង-ផ្ទះ-ជំនួញ ផ្សារ-ទំនិញ-រថ ៗ

៤.– សុំឲ្យគ្រូរើសពាក្យប្រាំ ឬប្រាំមួយម៉ាត់ ហើយឲ្យសិស្សធ្វើប្រយោគមួយ ៗ ជាមួយនឹងពាក្យមួយ ៗ ដូចអាទិត្យមុន ។

## សរសេរតាមសូត្រ

អាទិត្យទី១.– រឿងទីពីរ (ដល់និទានរឿងព្រេងឲ្យយើងស្តាប់)

ពាក្យពិបាក : អាយុ - កំផ្ទាល់ - គាត់ទុប - ប្រត់ - ធ្វើការធ្ងន់-ទូន្មានបន្តិច · កល់–ស្តាប់ ។

២– រឿងមើលទី ៣.– (សង្កាត់ខាងដើមទំព័រ ១៦)

៣– រឿងមើលទី ៣.– (សង្កាត់ត)

អាទិត្យទី ២.–

១– រឿងមើលទី ១– (សង្កាត់ខាងដើមទំព័រ ៤៩)

ពាក្យពិបាក.– គួរសម - មនុស្សពិការ - អាទិត្យ - កុមារ · អាយុ. មុខទ្វារ–ភូមិ - ដើម - ត្រជរ - កំ ។

២- រឿងមើលទី ១- (សង្កាត់ទី ២)

ពាក្យពិបាក .– បន្ទោស-ច្នេះ ចិត្តមេត្តា-ខុស-ដូច្នេះ ។

៣– រៀនមើលទី ២– (សង្កាត់ខាងដើមទំព័រ ៥៥)

ពាក្យពិបាក = ខ្ចប-ព្រឹទ្ធាចារ្យ-អាហារ-សិស្សអង្គុយ បរិភោគកន្ទេល-ប៉ុន្មាន ។

អាទិត្យទី ៣ និងទី ៤.-

## សរសេរតាមសូត្របញ្ជាក់

ឲ្យយករឿងមើលមកធ្វើវិធីសរសេរ តាមសូត្រចំនួន៥ ឬ ៦ បន្ទាត់ ហើយឲ្យហាត់សរសេរពាក្យពិបាកជាមុន ។

---

កុមារដ្ឋាន

## រៀនពាក្យហាត់ភាសា

អាទិត្យទី ១- **អាហារ**

បាយ សម្ល ឆា ត្រី ត្រីអាំង ត្រីជៀន ត្រីងៀត - ត្រីស្រស់ ត្រីប្រឡាក់ សាច់ជ្រូក សាច់គោ សាច់ជ្រូកជៀន សាច់គោងៀត សម្លជូរ សម្លប្រហើរ សម្លកកូរ អំបិល ប្រហុក ទឹកខ្មេះ ទឹកត្រី បាយដំណើប បាយខ្សាយ បបរ អន្លក់ ទឹកគ្រឿង បន្លែ មាន់ ទា ក្ងាន អណ្ដើក

កន្ទាយ ពងមាន់ ពងទា ស្ពៃ ដៃថាវ ខ្ទឹម ម្ទេស ឃ្លោក ក្រឡាប ននោង ត្រកួន ត្រកៀត. ទំពាំង អន្ទ្រម ទំកូវ ទ្រាប ដំណាប់

ជ្រាយ- ស្រួយ- កក ត្រជាក់ សាប ប្រៃ ប្រហើរ ក្រអូប ឈ្ងុយ ស្រស់ ក្រៀម ជូរ ឆៅ ឆ្អិន ផ្អែម ឆ្ងាញ់ ល្វីង ចត់ ។

ដាំបាយ ស្ល ជៀន អាំង ចំហុយ ស្ងោរ ស្ល ឆា ផ្សំគ្រឿង បង់គ្រឿង បំពិន ភ្លក្ស ស៊ី ហុត ស្រូប ទំពា លេប ។

## វត្ថុសម្រាប់ផឹក

ទឹក ទឹកទន្លេ ទឹកបឹង ទឹកអណ្ដូង ទឹកស្រះ ទឹកតែ ទឹកដាំ ទឹកកាហ្វេ ទឹកដំរង ទឹកម៉ាស៊ីន ទឹកភ្លៀង ទឹកកក ទឹកដោះគោ ទឹក-ស៊ីរ៉ូ ទឹកដាំ–

សាប ប្រៃ ក្រូវ ស្អាត កខ្វក់ ថ្លា ល្អក់ ឆ្អិន ឆៅ ក្ដៅ ត្រ-ជាក់ ខ្លាំង ល្អ សំរាំង–

ហូរ រង កក ពុះ ត្រង ច្រោះ បង្កើតរោគ ចុះ រាក បុក ផឹក លាង ងូត ទទួលទាន ពិសា សោយ ស្រង់

## ជម្ងឺ

គ្រុន ផ្ដាសាយ មួល រាក ចុះ ក្អួត ក្អក ប៉េស្ដ ចុកពោះ សៀត អា

សន្ទោគ របេង. យួន ស្រែង កមរមាស់ បួស ដំបៅ អុត កញ្ជ្រឹល អុតស្វាយ ឆ្កួតជ្រូក ស្កន្ធ ហឹត ប្រគ្រីវ ឬសដូងដុះ លឿង ទាបរេងរៃ ខ្វិន ឈឺក្អែក គ្រុនខ្លាំង មួលក្រហម ស្រែងគគ្រាត កមរលាយ ខ្វិន-ក្វេង ញាក់ រង៉ា កណ្តាស់ ក្អក ដុះ នោម ឈឺ ចាប់ តើត អស់-កម្លាំង ធ្វង ដរ ពល រកាំក្អែក ស្កន្ធជាន់ ផ្សះ ថែជម្ងឺ ផឹកថ្នាំ ពេទ្យមើល

របៀបបង្រៀន = គ្រូបង្រៀនតាមរបៀប មានគំរូចុះក្នុងទស្សនាវដ្តីលេខ១ឆ្នាំ១៩៥២–១៩៥៣ ត្រូវគ្រូប្រឹងពន្យល់ដោយបង្ហាញវត្ថុដោយឧទាហរណ៍ ឲ្យក្មេងច្បាស់លាស់ពាក្យនិមួយ ៗ មិនត្រឹមតែស្គាល់ពាក្យទេ ត្រូវឲ្យវាចេះប្រើពាក្យនោះក្នុងឃ្លាខ្លីៗ ងាយៗ

## រៀនមើលសរសេរ

អាទិត្យទី១. ទី២.

មេរៀនទី១០–១១ (សៀវភៅកុមារដ្ឋានទំព័រ២២.២៥)

យ- រ- ល- វ- ស- ហ- ឡ- អ-

នឹងបង្រៀនអក្សរទាំងនេះ សូមឲ្យប្រៀបធៀបនឹងតួអក្សរដែលបានរៀនហើយ

ឯរបៀបបង្រៀន សូមលោកគ្រូលៃបង្រៀនតាមគំនិតយោបល់-ម្នាក់ ហើយនឹងមើលតាមលំនាំចុះក្នុងទស្សនាវដ្ដីទី១ ឆ្នាំនេះ អាទិត្យទី៣ ទី៤

មេរៀនទី ១២ ទំព័រ ២៦-២៩-

ព្យញ្ជនៈ បន្ថែម

សូមឲ្យសរសេរនៅក្ដារខៀន ង- ញ ប ម យ រ ល វ ស ហ អ ហើយប្រាប់ពន្យល់ថាអក្សរទាំងនេះ អក្សរនិមួយ ៗ មានសម្លេងប្ដូរសព្ទពីកាលណាគេថែមវណ្ណយុត្តិ ឬ ង ង៉ ញ ញ៉ ប ប៉ ម ម៉ យ យ៉ រ រ៉ វ វ៉ ស ស៊ ហ ហ៊ អ អ៊ ៗ

សេចក្ដីចំណាំ: អក្សរ ណ ន ល មិនដែលមានវណ្ណយុត្តិមូសិកទន្តឬត្រីសព្ទពីលើឡើយ គ្រាន់តែប្រែ-សម្លេងតាមសព្ទដែលបង្អោនមក ៗ .

## តែងសេចក្ដី

សំរាប់ប្រថមភូមិបំពេញវិជ្ជា

កម្មវិធីសំរាប់ខែ—ពិព័ណ៌នាអំពីរុក្ខជាតិ - ពិព័ណ៌នាអំពីសត្វ ៗ

## ១- ពិព័ណ៌នាអំពីរុក្ខជាតិ

*សេចក្ដីលំនាំ*.– ក្នុងការតែងសេចក្ដីជំពូកនេះ គេអាចអធិប្បាយតាមគោលសេចក្ដីខាងក្រោម ៖

១– ទីកន្លែងដែលរុក្ខជាតិដុះ ។

២– ទិដ្ឋភាពរបស់រុក្ខជាតិទាំងមូល (រាង កំពស់ ពណ៌ ក្លិន)

៣– ពិព័ណ៌នាអំពីចំណែកសំខាន់ៗរបស់រុក្ខជាតិ (ដើម មែក ស្លឹក ផ្កា ផ្លែ)

៤– សេចក្ដីបញ្ចប់ (ផលប្រយោជន៍របស់រុក្ខជាតិ)

*រឿងតែង*.– ចូរធ្វើពិព័ណ៌នាអំពីដើមពោធិមួយដើមដែលដុះនៅក្នុងភូមិអ្នក ។

### សេចក្ដីអធិប្បាយ

១– នៅមុខវត្តក្នុងភូមិខ្ញុំបាទ មានដើមពោធិយ៉ាងធំមួយដើមដុះនៅកណ្ដាលទីវាលប្រហែលជិតមួយសតវត្សមកហើយ ។

២– ដើមពោធិនោះវាតមែកដ៏មានទំហំធំស្កឹមស្កៃពន់ពេក ។ កាលណាគេមើលពីចម្ងាយ គេឃើញដើមពោធិនោះលេចឡើងត្រសុំ ដូចជាឆ័ត្រមួយយ៉ាងធំលាតនៅកណ្ដាលទីលំហដើម្បីក្រាលម្លប់ដល់អ្នកដំណើរឬពួកគង្វាលគោ-ក្របីនៅពេលដែលព្រះអាទិត្យបញ្ចេញកំដៅខ្លាំង ។

៣– ដើមពោធិជារុក្ខជាតិមានដើមប្លែកពីរុក្ខជាតិនានា ៗ នៅខាងគល់មានឫសធំជាច្រើនប្រទាក់គ្នាយ៉ាងជិតស្និទ្ធផ្សំទំហំកើតឡើងជាដើមមួយយ៉ាងធំគោបពុំដុំ ៗ លុះមកដល់ដី ឫសធំៗទាំងនេះបែកចេញពីដើម ខ្លះលិចចូលទៅក្នុងដី ខ្លះវារទៅលើដីឆ្ពោះទៅគ្រប់ទិសទីៗដើមពោធិមានសំបកពណ៌សៀងខ្ចីតែមានផ្ទាំងក្រមរពណ៌ប្រផេះជាប់ជុំៗពី-ក្រៅនាំឲ្យមានពណ៌ពីរ ហើយមានផ្ទៃគ្រោតគគ្រើមផង ៗ

មែកបែកចេញពីគល់ប្រទាក់ប្រទើសគ្នានៅត្រង់កំពស់ប្រហែលពីរម៉ែត្រពីដីហើយមានស្លឹកពណ៌ខៀវចាស់ជាច្រើនបង្កៀតគ្នា ៗ ស្លឹកទាំងនេះភ្ជាប់ទៅនឹងមែកដោយទងវែងៗដែលជាហេតុនាំឲ្យទាញខ្យល់ណាស់ គេឮសូរស័ព្ទរ៉ាវៗបណ្ដាលពីស្លឹកប៉ះគ្នាស្ទើរតែឥតស្រាកដោយត្រូវខ្យល់បក់បោកបន្តិចបន្តួច លាយនឹងសម្រែកខ្ញៀវខ្ញារនៃបក្សាបក្សីដែលនាំគ្នាមកអាស្រ័យផ្លែពោធិ ៗ ពីគ្រប់មែកមានឫសតូចធំជាច្រើនធ្លាក់មកខ្លះអណ្ដែតយោលទៅយោលមកដូចខ្សែព្យួរ ខ្លះចាក់ចូលទៅក្នុងដីមានសណ្ឋាន ដូចជាទ្រនល់ ៗ.

នៅពេលឈប់សំរាករៀន ខ្ញុំបាទចូលចិត្តទៅលេងជាមួយនឹងគូកនខ្ញុំបាទនៅក្រោមដើមពោធិនេះ ដែលបាំងម្លប់ដ៏ត្រជាក់ឲ្យយើងខ្ញុំលេងល្បែងផ្សេង ៗ យ៉ាងរីករាយ ដោយឥតរវាងនឹងកំដៅថ្ងៃឡើយ ៗ

កាលណាមានភ្លៀងធ្ងន់ៗ ខ្ញុំបាទយកខោអាវទៅលាក់នៅតាមរន្ធ ដែលមានជាច្រើននៅជុំវិញគល់ពោធិ ។

៤- ដើមពោធិនៅមុខវត្តនៃភូមិខ្ញុំបាទ ជារុក្ខជាតិមួយដើមធំស្កឹមស្កៃប្រកបដោយស្លឹកគ្រសុំគ្រសាយលូតខ្ពស់ គ្របលើរុក្ខជាតិនានា ។ អ្នកនៅក្នុងភូមិទាំងប៉ុន្មាន តែងគោរពរុក្ខជាតិដ៏មានអាយុនេះណាស់ ។

៥- ពិពណ៌នាអំពីសត្វ

រៀងតែង- ចូរអ្នកធ្វើពិពណ៌នាអំពីគោមួយ ដែលអ្នកបានសង្កេត ព្រមទាំងអធិប្បាយអំពីប្រយោជន៍របស់សត្វនេះផង ។

ការរៀបចំ- អ្នកបានពិនិត្យគោនោះនៅទីណា ? គោនោះតូចឬធំ ? សម្បុរអ្វី ? ខ្លួនវាមានសណ្ឋានដូចម្ដេច ? – កំប៉ោង ? – ស្ដើង ? កបែបណា ? ប៉ើងបែបណា ? ត្រគាកឬទ្រគាកបែបណា ? កន្ទុយនិងជើងបែបណា ? ក្បាលវាតូចឬធំ ? ស្នែងត្រចៀក មាត់ ថ្គាម មានលក្ខណៈបែបណា ? គេធ្វើដូចម្ដេចដើម្បីនឹងដឹកវាបានស្រួល ? ដំណើរវាបែបណា ? វាជាសត្វកាចឬស្លូត ? – មានអំណត់ឬទេ ? វាផ្ដល់ប្រយោជន៍អ្វីឲ្យយើងខ្លះ ? – ពេលវានៅរស់ពេលវាស្លាប់ទៅ ? ស្បែកឆ្អឹងស្នែងវាមានប្រយោជន៍អ្វី ?

ចូរអ្នកអធិប្បាយបង្ហាញ ឲ្យឃើញថាគោជាសត្វជំនួយមួយយ៉ាង សំខាន់ដល់អ្នកកសិករ ។

## គោលសេចក្ដី

១– កន្លែងដែលអ្នកបានពិនិត្យគោ –

២– រូបរាងកាយ៖ មាឌ រាង សម្បុរ –

៣– ចំណែកខ្លួនវាដែលមានលក្ខណៈប្លែកពីគេ (ដងខ្លួនក្បាល–ជើង)

៤– ដំណើរវា ចរិតវា ។

៥– ប្រយោជន៍ដែលវាផ្ដល់ឲ្យយើង ។

---

អាទិកដ្ឋាន

## តែងសេចក្ដី

ចូលតែងសេចក្ដីតាមកំនូរ

ក ) ពាក្យប្រារព្ធបទដើមដំរាលសេចក្ដី

ខ ) អាការសម្ដែងឡើងតាម ( គឺប្រព្រឹត្តធ្វើអ្វី )

គ ) បញ្ចប់សេចក្ដី ( គឺបទដំបូន្មានយ៉ាងខ្លី )

ដំបូន្មាន – សូមឲ្យលោកគ្រូរកគំនូរដំណាងធ្វើការអ្វីមួយឲ្យកូនសិស្សតែងសេចក្ដីតាម ។

ការតែងសេចក្ដីត្រូវចែកជាពីរខណៈ ។ ខណៈដំបូងត្រូវចោទរកពាក្យនឹងប្រើការតែងសេចក្ដី ។ ខណៈក្រោយត្រូវកែចំពោះមុខកូនសិស្សពាក្យខុស, អក្សរខុស តែសេចក្ដីនោះគ្រូត្រូវកែឲ្យស្រេចមក, មុនកែចំពោះមុខកូនសិស្ស គឺមួយអាទិត្យធ្វើកែតែងសេចក្ដីមួយ ។

តែងសេចក្ដីទី ១

## អំពីភូមិអ្នក

ចូរអ្នកតែងសេចក្ដីអធិប្បាយអំពីភូមិអ្នកតាមពាក្យចោទខាងក្រោមនេះ ។

ភូមិអ្នកឈ្មោះភូមិអ្វី, នៅក្នុងឃុំណា, ស្រុកណា, ខេត្តណា ? ភូមិនោះធំឬតូច ? ព្រំខាងជើងទល់នឹងអ្វី ? ខាងត្បូងទល់នឹងអ្វី ? ខាងកើតទល់នឹងអ្វី? ខាងលិចទល់នឹងអ្វី ? នៅក្នុងភូមិអ្នកមានផ្ទះប្រហែលចំនួនប៉ុន្មានខ្នង ? ផ្ទះទាំងនោះសង់ទាបឬខ្ពស់ពីដី? ពីព្រោះអ្វីបានជាខ្មែរចូលចិត្តសង់ផ្ទះខ្ពស់ពីដី ?

## គំរូតែងសេចក្ដី

ភូមិខ្ញុំឈ្មោះភូមិ..........នៅក្នុងឃុំ.........ស្រុក.........ខេត្ត.......... ភូមិនោះមិនធំប៉ុន្មានទេ ព្រំខាងជើងទល់នឹង.........ខាងត្បូងទល់នឹង........... ខាងកើតទល់នឹង.........ខាងលិចទល់នឹង.........។ នៅក្នុងភូមិខ្ញុំ មានផ្ទះចំនួនប្រហែលពីររយខ្នង ។ ផ្ទះទាំងនោះសង់ខ្ពស់ពីដីទាំងអស់ ។ បានជាខ្មែរចូលចិត្តសង់ផ្ទះខ្ពស់ពីដី ព្រោះឲ្យស្រឡះក្រោមដោយសំអាត–ផងនឹងដាក់ប្រដាប់ប្រដារសម្រាប់ធ្វើស្រែចំការ ដាក់កីត្បាញ ដាក់ត្បាល់កិន ដាក់គ្រែសម្រាប់អង្គុយលេងនៅពេលក្ដៅផង ។

## តែងសេចក្ដីទី២

ចូរតែងសេចក្ដីអធិប្បាយអំពីប្រដាប់ប្រដារប្រើធ្វើស្រែចំការតាមពាក្យចោទខាងក្រោមនេះ ។

អ្នកនៅស្រុកស្រែឬស្រុកចំការ ? នៅស្រុកអ្នកគេរកស៊ីធ្វើអ្វីខ្លះ ? អ្នកស្រុក នៅភូមិអ្នកគេប្រើប្រដាប់អ្វីខ្លះ ដែលនឹងធ្វើស្រែចំការ ? បើសិនជាគ្មានគ្រឿងប្រដាប់ទាំងអស់នេះគេធ្វើស្រែចំការបានឬទេ ? ពីព្រោះអ្វី ?

# តែងសេចក្ដី ទី៣

## អំពីសួនច្បារ

សូមលោកគ្រូរៀបចំរឿងតែងនេះ

---

បរិច្ឆណាដ្ឋាន

| តែងសេចក្ដី |
| --- |

សរុបរឿង = អំពីផ្ទះ

លំនាំ— ឯរបៀបតែងសេចក្ដីត្រូវតែគ្រូតែងពាក្យចោទដាក់នៅលើក្ដារខៀនបញ្ជូរឲ្យសិស្សឆ្លើយពីព្រោះវាចេះសរសេរគួរសមហើយ ប៉ុន្តែមុននឹងឲ្យវាអធិប្បាយអំពីរឿងអ្វីទីមួយ ៗ គប្បីគ្រូសួរតែមាត់ទទេសិន ឯចម្លើយមួយឃ្លា ៗ ត្រូវឲ្យសិស្សថាតាមគ្នាបាន ៤ ឬ ៥ ដង តទៅទៀត លុះស្រេចកាលណាហើយត្រូវគ្រូអធិប្បាយមួយទ្រួសឲ្យសិស្សស្ដាប់ឡើងវិញរួចសឹមឲ្យវាធ្វើនៅសៀវភៅ ៗ

## តែងសេចក្ដីទី ១

# អំពីផ្ទះអ្នក

ផ្ទះអ្នកសង់នៅភូមិណា? ផ្ទះនោះសង់ទាបឬខ្ពស់ពីដី? បែរមុខទៅទិសខាងណា? សសរធ្វើពីឈើអ្វី? ដំបូលប្រក់អ្វី? ជញ្ជាំងធ្វើពីអ្វី? ក្រាលរនាបឬស្សីឬក្រាលក្ដារ? ផ្ទះអ្នកមានប៉ុន្មានល្វែង? អ្នកស្រឡាញ់ផ្ទះអ្នកឬទេ? ពីព្រោះអ្វី?

## គំរូសេចក្ដី

ផ្ទះខ្ញុំសង់នៅភូមិ.......... ។ ផ្ទះនោះសង់ខ្ពស់ពីដី ។ បែរមុខទៅទិសខាង ..... ..... សសរធ្វើពីឈើក្រកោះ ។ ដំបូលប្រក់ក្បឿង ។ ជញ្ជាំងធ្វើពីក្ដារ ។ ក្រាលក្ដារ ផ្ទះខ្ញុំមានបីល្វែង ។ ខ្ញុំស្រឡាញ់ផ្ទះខ្ញុំណាស់ ។ ពីព្រោះខ្ញុំកើតនៅទីនោះនិងនៅជួបជុំឪពុកម្ដាយបងប្អូនខ្ញុំផង ។

## តែងសេចក្ដីទី ២

ចូរតែងសេចក្ដីអធិប្បាយអំពីឈើដែលគេយកមកធ្វើគ្រឿងផ្ទះ តាមពាក្យខាងក្រោមនេះ ។

ឈើអ្វីខ្លះដែលគេយកមកធ្វើជាគ្រឿងផ្ទះ ? ឈើទាំងនោះមានដុះនៅឯណា ? គេធ្វើដូចម្ដេចទើបបានឈើពីព្រៃមកប្រើការ ? គេធ្វើដូចម្ដេចទៀតទើបបែកឈើបានជាគ្រឿងផ្ទះ ។ គេយកឈើអ្វីធ្វើជាសសរ ? ឈើអ្វីធ្វើជាគ្រឿងលើ ? អ្នកចូលចិត្តនឹងឈើទាំងនោះឬទេ ? ពីព្រោះអ្វី ?

## តែងសេចក្ដីទី ៣

ចូរតែងសេចក្ដីអធិប្បាយអំពីជាងឈើនៅក្នុងភូមិអ្នកតាម ពាក្យចោទខាងក្រោមនេះ ។

នៅភូមិអ្នកមានជាងឈើឬទេ ? ជាងនោះឈ្មោះអ្វី ? គាត់សង់រោងនៅខាងណាភូមិអ្នក ? នៅក្នុងរោងអ្នកឃើញមានប្រដាប់អ្វីខ្លះសម្រាប់ជាងធ្វើការ ? ជាងឈើមានប្រយោជន៍នឹងយើងឬទេ ? ពីព្រោះអ្វី ?

---

## អាទិកដ្ឋាន

## នព្វន្ត

អាទិត្យទី ១— លេខគុណ

បើខ្ញុំទិញដងប៉ាកកា ៣ មួយថ្លៃ ៥ សេន នោះខ្ញុំនឹងចេញថ្លៃឲ្យគេយ៉ាងដូច្នេះ ៗ

៥ សេន + ៥ សេន + ៥ សេន = ១៥ សេន

គឺថាថ្លៃចំនួនតាំង ៣ ដងនេះស្មើគ្នាតាំងអស់ ឬខ្ញុំត្រូវធ្វើលេខគុណដូច្នេះវិញ ៗ ខ្ញុំសរសេរ ៥ សេន × ៣ = ១៥ ស ៗ ៥ ជាលេខតាំង ដែលខ្ញុំថាដដែល ៗ ឡើងវិញបីដង ៗ ៣ ជាមេគុណ ៗ លេខតាំងគឺចំនួន ដែលគេហៅដដែល ៗ ឡើងវិញ ៗ មេគុណគឺចំនួនប៉ុន្មានដងដែលគេថាដដែល ៗ ឡើងវិញ ៗ ផលគឺជាចំនួនសរុបលេខគុណនេះ ៗ

លេខតាំង × មេគុណ = ផល

សេចក្ដីសំខាន់.— ការដែលមានប្រយោជន៍ជាទីបំផុតក្នុងលេខគុណត្រូវឲ្យរៀនចេះចាំស្ទាត់នៃលេខគុណ ៗ

វិធីហាត់គិតមាត់ទទេ.— ១— សូមសាចក្រៀនមេលេខ-គុណតាំងមេពីរឡើងវិញ រហូតមកដល់មេដប់ ៗ ២— ពែងមួយថ្លៃ ៨ សេន ពែង ៦ ថ្លៃប៉ុន្មាន ? ពែង ៨ ថ្លៃប៉ុន្មាន ? ពែង ៩ ថ្លៃប៉ុន្មាន ? ពែង ៧ ថ្លៃប៉ុន្មា? ពែង ១០ ថ្លៃប៉ុន្មាន ? ៗ ខ្ញុំរកប់តើត្រូវជាប៉ុន្មាន

ម្ជុល ៥ ប្រាំបួនដង ឡេវអាវ ៨ ប្រាំបួនដង កន្ត្រៃ ៤ ប្រាំបួនដង ហុងអម្បោះ ៩ ដប់ដង ។

វិធីហាត់សរសេរ.— ១- អ្នកជំនួញតូចតាំងម្នាក់ ទិញកៅអី ៣៧ ថ្លៃ ៤ រៀលមួយ អ្នកនោះលក់តាំងអស់ទៅបំណេញបាន ៣២- រៀល តើថ្លៃលក់កៅអីតាំងអស់នោះប៉ុន្មាន ? ២.— សួនមួយរាង ៤ ជ្រុង ទ្រវែងបណ្ដោយ ១៨ ម៉ែត្រ ទទឹង ១២ ម៉ែត្រ ជុំវិញសួននោះគេធ្វើរបង ថ្លៃ ១៧ សេន ១ ម៉ែត្រ តើថ្លៃរបងនោះប៉ុន្មានរៀល ។

២.— មេគុណមានលេខតែមួយខ្ទង់

ជាងម្នាក់មានប្រាក់ខែ ២៣ រៀលក្នុង ១ ខែ បានប្រាក់ប៉ុន្មាន បើជាងនោះធ្វើការបាន ៣ ខែ ។ ក្នុង ៣ ខែជាងនោះបើកប្រាក់បាន- ២៣ រៀល ៣ ដង ឬ ២៣៛ × ៣ ។

នឹងធ្វើលេខគុណបែបដូច្នេះ គេត្រូវដាក់បែបនេះ

$$\begin{array}{r} ២៣៛ \\ \times ៣ \\ \hline ៦៩៛ \end{array}$$

គេថា ៣ បីដង ៩ ខ្ញុំសរសេរ ៩ រួចខ្ញុំថា ៣ ពីរដង ៦ ខ្ញុំសរសេរ ៦ ខាងក្រោម ដល់លេខនេះគឺ ៦៩ រៀល ។

វិធីហាត់មាត់ទទេ.– ចូរធ្វើលេខដូចមានដាក់ឲ្យមកខាងក្រោមនេះ :

៣៣ × ៣ = ៦២ × ៣

៥១ × ៤ = ២៤ × ២

ចំណោទ.– អ្នកជំនួញសំពត់ម្នាក់ទទួលសំពត់ ៨ ផាប់ប្រវែង ១២ ម៉ែត្រ មួយផាប់ និង ៧ ដុំទៀតប្រវែង ១០ ម៉ែត្រមួយដុំ ៗ អ្នកជំនួញនោះបានទទួលសំពត់ប៉ុន្មានម៉ែត្រ? ២– អ្នកជំនួញសត្វពាហនៈម្នាក់បានលក់ក្របី ៤ ថ្លៃ ៤២០ រៀលមួយ ឃើញចំណេញទាំងអស់ ៤៨០ រៀល តើថ្លៃដើមក្របីទាំង ៤ នេះប៉ុន្មាន?

## លេខគុណមានត្រាទុក

ខ្ញុំជួលមនុស្ស ៣ នាក់កើបសណ្ដែកប្រកបារ ហើយខ្ញុំឲ្យឈ្នួល ៣៥ សេនម្នាក់ៗ ៗ តើខ្ញុំត្រូវឲ្យឈ្នួលប៉ុន្មានទាំង ៣ នាក់នេះ ៗ

ខ្ញុំសរសេរយ៉ាងនេះ : ៣៥

× ៣

―――

១០៥

ខ្ញុំថា ៣ ប្រាំដង ១៥ ឬ ៥ សេន ខ្ញុំសរសេរ ៥ នឹងប្រាក់គាក់

មួយដប់សេន ឬ ១០ សេន ១ដង ហេតុនេះខ្ញុំត្រូវគ្រាទុកមួយ ៗ កាក់ ៣ ៗ ដង ៩ កាក់ ហើយនឹងគ្រាទុក ១ នោះត្រូវជា ១០ ខ្ញុំសរសេរ ១០ គឺ ១០៥ សេន ខ្ញុំត្រូវឲ្យឈ្មួលទាំងអស់ ១០៥ សេន ។

វិធីហាត់សរសេរ.- ហេតុអ្វីនៅក្នុងលេខគុណមានគ្រាទុក គេត្រូវផ្ដើមគុណពីខាងស្ដាំ មិនឲ្យផ្ដើមគុណពីឆ្វេង លេខគ្រាទុកមានហួសពីលេខ ៨ ឬទេ ៖ ហេតុអ្វី? អ្នកត្រូវរកយ៉ាងដូចម្ដេចឲ្យបានឆាប់ ឃើញថ្លៃគោបីនឹម និងគោ ២ នឹម បើគោមួយថ្លៃ ៥៧ រៀល ?

វិធីហាត់សរសេរ ១- ចូរធ្វើលេខដូចមានខាងក្រោមនេះ

៥៦៛ × ៦ =　　　៧៥៛ × ៧ =　　　៩៨៛ × ៨ =

៣៩២ ម × ៣ =　　៧២៤ ម × ៥ =　　៦៥៩ ល × ៤ =

អាធិត្យទី២.- លេខចែក (ដើងហារមានលេខតែមួយតួ)

ខ្ញុំចង់ចែកស្លាបប៉ាកកា ២៤ ឲ្យសិស្ស ៤ នាក់ តើម្នាក់ ៗ ត្រូវបានប៉ុន្មាន ៗ រកចំណែកម្នាក់ ៗ នោះត្រូវយកចំនួន ២៤ មកចែកនឹង ៤ ។ យើងគិតថាក្នុង ២៤ តើមាន ៤ ប៉ុន្មានដង ។ ថាមាន ៤ ប្រាំមួយដង ដូច្នេះ សិស្សម្នាក់ ៗ ត្រូវបានស្លាបប៉ាកកា ៦ ។ គេសរសេរលេខយ៉ាងនេះ

២៤ : ៤ = ៦ ហើយដើម្បីនឹងធ្វើលេខចែកយ៉ាងនេះដោយងាយ នោះត្រូវរៀនមេលេខឲ្យស្ទាត់ ។

សូមមើលហើយបង្រៀនតាមសៀវភៅក្បួនគព្វន្តទំព័រទី២៣ដល់៤៧

អាទិត្យទី៣.– ១ ថ្លៃទិញវត្ថុសរុប

ឧបមា: មាខ្ញុំលក់គោបក្រយានមួយថ្លៃ ៧៣៥៛ គាត់បានចំណេញទាំងអស់១៣៥៛ តើគោបក្រយាននោះទិញមកថ្លៃប៉ុន្មាន ?

នឹងរកថ្លៃទិញវត្ថុសរុបធ្វើអ្វីនីមួយ ត្រូវយកប្រាក់ចំណេញទៅកាត់ថ្លៃលក់ចេញគឺ:

៧៣៥ – ១៣៥ = ( លក់ – ចំណេញ ) ឃើញថាគោបក្រយាននោះទិញមកថ្លៃ ៦០០៛០០ ។

វិធីគិតមាត់ទទេ - អ្នកស្រែម្នាក់លក់ចៀមមួយថ្លៃ២៨៣ រៀល ហើយបានចំណេញ ៥០ រៀល តើចៀមនោះទិញមកថ្លៃប៉ុន្មាន ។

ស្រីម្នាក់លក់ក្រមា ៥ ថ្លៃ ៤៣ រៀល ហើយបានចំណេញ ១៣៛ តើក្រមាទាំងអស់ទិញមកថ្លៃប៉ុន្មាន ?

វិធីបាត់សរសេរ– ចំណោទ.–

ឪពុកខ្ញុំលក់មួក ៥ បានថ្លៃ ១៣៣ រៀលមួកមួយ ហើយបានចំណេញ

ទាំងអស់ ១២៥ រៀល តើមួកទាំងអស់ទិញមកថ្លៃប៉ុន្មាន ?

## ២– ថ្លៃទិញរបស់និមួយ ៗ

ឧបមា: ឈ្មួញម្នាក់លក់ទូ ៣ ថ្លៃទាំងអស់ ៣៥០រៀល ហើយបាន ចំណេញ ៥០ រៀល តើថ្លៃដើមទូមួយទិញមកថ្លៃប៉ុន្មាន ។

មុននឹងរកថ្លៃដើមទូនិមួយ ៗ ត្រូវរកថ្លៃទូទាំង ៣ សិនទើបយកថ្លៃដើមទូ ទាំងអស់មកចែកនឹងចំនួនទូនោះគឺ :

ថ្លៃដើមទូទាំង ៣ គឺ ( ថ្លៃលក់ - ចំណេញ )

៣៥០រ – ៥០ = ៣០០រ

ថ្លៃដើមទូមួយ: ( ថ្លៃដើម : ចំនួនរបស់ដែលទិញ )

៣០០រ : – ៥០ = ៣០០រ

ឆ្លើយថាទូនិមួយ ៗ ទិញមកថ្លៃ ១០០រ

វិធីហាត់គិតមាត់ទទេ–

១– ស្រីម្នាក់លក់មាន់ ៣ ថ្លៃ ៣៣ រៀល ហើយបានចំណេញ ១៥ រៀល តើមាន់មួយទិញមកថ្លៃប៉ុន្មាន

២– ចិនម្នាក់លក់ស្រាទំពាំងបាយជូរ ៥ ដបថ្លៃ ៥៥រ ហើយចំណេញ ១៥រៀល តើស្រាទំពាំងបាយជូរមួយដបទិញមកថ្លៃប៉ុន្មាន ។

ចំណោទ. យួនម្នាក់លក់មួកស្លឹក ៣ ឡូថ្លៃ ២២៦ រៀល បាន ចំណេញ ៣៦ រៀល ។ តើមួកនិមួយ ៗ ទិញមកថ្លៃប៉ុន្មាន ។

## វង្វាស់វង្វាល់

អាធិត្យទី១ .— អំពីក្រដាសប្រាក់សំរាប់ចាយនៅប្រទេសឥណ្ឌូចិន

ប្រាក់ក្រដាសមួយរៀល ៥ រៀល ។

សូមយកប្រាក់ក្រដាសមកបង្រៀន ហើយឲ្យបានច្រើនយ៉ាងផង ក្រដាសប្រាក់ជាន់ចាស់ នឹងក្រដាសប្រាក់ជាន់ថ្មី ។ បង្ហាញក្រដាសប្រាក់រៀលឲ្យសិស្សមើល នេះក្រដាសប្រាក់ ១ រៀលមានសរសេរលេខចំនួន ១ រៀលជាប់នៅនេះផង ដើម្បីកុំឲ្យច្រឡំ មានពណ៌ក្បាច់របទាក់ស្អាតហើយ មានរូបយួនប្រុសស្រីទៀតផង ។ ក្រដាសប្រាក់ ១ រៀលជាន់ថ្មីខុសពីក្រដាសប្រាក់ ១ រៀលជាន់ចាស់ដោយទំហំនឹងគំនូរ ។ ក្រដាសប្រាក់ប្រាំរៀលជាន់ថ្មីមានរូបប្រាសាទខុសពីក្រដាសចាស់ដែលមានរូបក្រអោក ។ ល ។ ក្រដាសប្រាក់ស្រាល គេយកទៅណាមកណាបានដោយងាយដល់អ្នកជំនួញទាំងឡាយ ប៉ុន្តែត្រូវប្រយ័ត្នក្រដាសប្រាក់ក្លែងក្លាយ គេចំណាំនឹងលេខនឹងសាច់ក្រដាស ឬនឹងពណ៌ក្រដាស ។ ល ។

ហាត់គិតមាត់ទទេ= ក្រៅពីប្រាក់រៀល ឬប្រាក់កាក់មានប្រាក់អ្វីខ្លះសំរាប់ចាយនៅស្រុកយើង ? ប្រាក់ក្រដាស ១ រៀល នឹងប្រាក់រៀលដូចគ្នាឬទេ ។ ពីព្រោះអ្វីបានជាគេយកក្រដាសធ្វើជាប្រាក់ចាយ ? ក្នុងប្រាក់ក្រដាស ១ រៀលនឹងប្រាក់សាច់ ១ រៀលប្រាក់ណាមានថ្លៃជាង ? ពីព្រោះអ្វីបានជាមានថ្លៃដូចគ្នា ? ក្នុងប្រាក់ក្រដាស ១ រៀលមានប៉ុន្មានកាក់ ។ល។

ហាត់នឹងក្តារខៀន.– ត្រូវជាប៉ុន្មាន ២៥ នឹង ៣៨ រៀល ១០៧ នឹង ៨០ រៀល ។ ប្រាក់ក្រដាស ៥ រៀល ៣ សន្លឹកនឹងក្រដាស ១ រៀល ២៦ សន្លឹកត្រូវជាប៉ុន្មានរៀល ។ល។

អាទិត្យទី២.– ប្រាក់ក្រដាស ២០ – ១០០ រៀល ។

សូមធ្វើដូចអាទិត្យទី ១ ខាងលើនេះ ពន្យល់សិស្សអំពីពណ៌ ទំហំក្រដាសប្រាក់ ២០ រៀលនឹង ១០០រៀលឲ្យស្គាល់ប្រាកដ ។

ហាត់គិតមាត់ទទេ.– ក្រដាសប្រាក់មានប៉ុន្មានយ៉ាង ? ក្រ-ដាសប្រាក់អ្វីខ្លះ? ក្រដាសប្រាក់ទាំងនេះដូចគ្នាឬទេ ? ខុសគ្នានឹងអ្វី? ។ល។

ហាត់គិតនឹងក្តារខៀន. ត្រូវជាប៉ុន្មានរៀល ២៧ រៀលនឹង ៣៣ រៀល ។ ១៧៥រ នឹង ១៤០រ ។

ហាត់សរសេរ.— មាខ្ញុំលក់ស្រូវបាន ៤ ថែន លក់ពោតបាន ១២០ រៀល មាខ្ញុំបានប្រាក់ទាំងអស់..............រៀល ។

---

## បរិវច្ឆណាដ្ឋាន




មេរៀនទី១.— ចំនួនពី ៤៩៩ ដល់ ៥៩៩. ការរៀនរាប់ រៀនអាន រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន.— បង្កឹះនិងបំពង់សំរាប់ដាក់បង្កឹះ ខ្ទង់រាយ ខ្ទង់ដប់ ខ្ទង់រយ




របៀបបង្រៀន.— គ្រូដាក់បង្កឹះ ៤ ក្នុងបំពង់ខ្ទង់រយ បង្កឹះ ៣ ក្នុងបំពង់ខ្ទង់ដប់ បង្កឹះ ២ នៅបំពង់ខ្ទង់រាយ ហើយពន្យល់

សិស្សជារបៀបសួរសាកឲ្យឃើញថាជាចំនួន ៤៣៦

ព្រោះលេខ ៤ នៅខ្ទង់រយ = ៤

- ៤ - រយ = ៤

- ៣ - ដប់ = ៣០

- ៦ - កយ = ៦

- គ្រូសរសេរចំនួន ៤៣៦ នេះនៅលើក្ដារខៀនហើយពន្យល់របៀបសរសេរចំនួននោះផង

- ឲ្យសិស្សអានចំនួននោះ

- ឲ្យសិស្សសរសេរចំនួននោះនៅលើក្ដារឆ្នួន

- គ្រូថាចំនួនឲ្យសិស្សរៀបបន្ទះដាក់បំពង់

- គ្រូដាក់បន្ទះកន្ទុំបំពង់ឲ្យសិស្សថាចំនួន ធ្វើរបៀបនេះរហូតដល់ចំនួន ៩៩៩ ។

ការហាត់បញ្ជាក់ឡើងវិញ .—

ក. ការអានចំនួន.— គ្រូបង្អុលចំនួនឲ្យសិស្សអាន - គ្រូថាចំនួនឲ្យសិស្សបង្អុល

ខ. ការហាត់សរសេរចំនួន.- គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួន

- ការហាត់សរសេរនៅក្នុងសៀវភៅ.– សូមតែងការហាត់ដាក់ឲ្យសិស្សធ្វើផង ។

មេរៀនទី២.– ចំនួនដល់ ៥៩៩-រៀនធ្វើលេខបូកនិងលេខសងមានត្រាទុក ។

របៀបបង្រៀន.–

១– ការហាត់គិតមាត់ទទេ-ឲ្យសិស្សរាប់បន្ថែមពីរៗ បីៗ បួនៗ ប្រាំៗ រាប់បន្ថយមកវិញ

២– ពន្យល់របៀបធ្វើលេខនៅលើក្ដារខៀន (គ្រូធ្វើជាមួយសិស្ស ហើយពន្យល់របៀបត្រាទុក ។

៣– ឲ្យសិស្សធ្វើលេខនៅលើក្ដារខៀនឲ្យរាប់ថាតាមការដែលរាធ្វើៗ

៤– ឲ្យសិស្សធ្វើលេខនៅលើក្ដារឆ្នួន

៥– ការហាត់សរសេរនៅក្នុងសៀវភៅ ។

សូមតែងការហាត់នេះផង ។

មេរៀនទី៣.– ចំនួនពី ៥៩៩ ដល់ ៦៩៩

ការរៀនរាប់ រៀនអាន រៀនសរសេរចំនួន

មេរៀនទី៤.– ចំនួនដល់ ៦៩៩ - មេលេខគុណ ៦ ៧ ។

រៀនគុណចំនួនទឹង ៦-៧ ។

មេរៀនទី៥.– ចំនួនពី ៦៩៩ ដល់ ៧៩៩.

ការរៀនរាប់ រៀនអាន រៀនសរសេរចំនួន

មេរៀនទី៦.– ចំនួនដល់ ៧៩៩ - រៀនចែកចំនួនជា ៦ - ៧

មេរៀនទី៧.– ចំនួនដល់ ១,០០០

ការរៀនរាប់ រៀនអាន រៀនអានសរសេរចំនួន ។

## រង្វាស់រង្វាល់

មេរៀនទី ១.– អំពីហិកតូម៉ែត្រ (ហ.ម.)

របស់សំរាប់បង្រៀន.– ប្រវាក់ដេកាម៉ែត្រ

របៀបបង្រៀន.– នាំសិស្សចេញទៅឯទីធ្លាសាលារៀន ហើយ នាំសិស្សវាស់ប្រវែង ១០ ដ.ម. នឹងប្រវាក់ដេកាម៉ែត្រ រួចនាំសិស្ស ពិនិត្យមើលចម្ងាយ ១០០ ម. ដែលទើបនឹងវាស់នោះដើម្បីឲ្យសិស្សចេះ ស្មានប្រវែង ១០០ ម. ។

នាំសិស្សចូលមកក្នុងថ្នាក់រៀនវិញ ដើម្បីនឹងពន្យល់ដោយការសួរសារកនាំសិស្សនិយាយ

ពាក្យចោទ.– អម្បាញ់មិញនេះយើងវាស់ប្រវែងប៉ុន្មានដេកាម៉ែត្រ ៗ ក្នុង ១០ ដា.ម. មានប៉ុន្មានម៉ែត្រ ៗ ប្រវែង ១០ ដា.ម. ឬ ១០០ ម. គេហៅអ្វី ៗ គ្រូសរសេរពាក្យហិកតូម៉ែត្រនៅលើក្តារខៀនជាអក្សរគ្រប់តួនឹងជាអក្សរកាត់ ៗ បើត្រូវការវាស់ប្រវែង ១ ហ.ម. គេប្រើរង្វាស់អ្វី ៗ ហិកតូម៉ែត្រមានរង្វាស់ជាក់ស្តែងឬទេ ៗ

ការហាត់គិតមាត់ទទេ.–

៤ ហ.ម. = .... ដា.ម. ឬ .... ម ៗ

៣ ហ.ម. = .... ដា.ម. ឬ .... ម ៗ

៥០ ដា.ម. = .... ហ.ម. ឬ .... ម ៗ

២០០ ម. = .... ហ.ម. ឬ .... ដាម ៗ

៣០០ ម+ ៤០ដាម = ...... ហ.ម. ៗ

៥ ហ.ម.– ២០០ ម = ...... ដា.ម. ៗ

ការហាត់សរសេរ.– សូមតែងការហាត់សរសេរនេះផងតាមរបៀបការហាត់ខាងលើនេះ ៗ

មេរៀនទី២.– អំពីហិកតូលីត្រ (ហ.ល.)

មេរៀនទី៣.– អំពីហិកតូក្រាម (ហ.ក្រ.)

មេរៀនទី៤.– អំពីផ្ទៃបួនជ្រុងទ្រវែង- និងរបៀបរកបរិវេណសូមមើលតាមរបៀបរៀបចំនៅក្នុងទស្សនាវដ្តីឆ្នាំទី ៣ លេខ ៤ នៅទំព័រទី៥៨ និង ៥៩ ។ –

---

## កុមារដ្ឋាន

**សព្វគ្រ**

មេរៀនទី១ – ចំនួនពី ២៩ ដល់ ៣៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន ។

របស់សំរាប់បង្រៀន .– ចង្កឹះបាច់ បី បាច់ និងចង្កឹះរាយ ៩ ឬប្រាក់កាក់១០សេន ៣ និងលុយ១សេន៩ ។

របៀបបង្រៀន .–

១ការហាត់គិតមាត់ទទេ – នាំសិស្សរាប់បន្ថែមបី ៗ ពី ១ ដល់ ២៩ –
រាប់បន្ថយបី ៗ មកវិញ ៗ

២– រៀនចំនួន ៣០ គ្រូបង្ហាញបង្កើះ ២៩ ហើយបន្ថែម ១ ទៅ-
ទៀត ត្រូវជា ៣០ ។ ពន្យល់ ក្នុង ៣០ មាន ១០ ប៉ុន្មានដង

៣– រៀនមើលចំនួន ៣០ គ្រូសរសេរចំនួន៣០នៅលើក្ដារខៀន-
នាំសិស្សរៀនមើលចំនួននោះ

៤- រៀនសរសេរចំនួន៣០ គ្រូពន្យល់របៀបសរសេរ ចំនួន៣០
ឱ្យសិស្សសរសេរនៅលើក្ដារខៀនរួចឱ្យសរសេរនៅលើក្ដារថ្មួន ៗ

ធ្វើតាមរបៀបខាងលើនេះរហូតដល់ ៣៩

៥– ការហាត់បញ្ចាក់ឡើងវិញ

ក) ឱ្យសិស្សលើកចង្កើះបង្ហាញតាមចំនួនដែលគ្រូថា

ខ) ឱ្យសិស្សមើលថាចំនួនដែលគ្រូចង្អុល

គ) ឱ្យសិស្សសរសេរចំនួននៅលើក្ដារថ្មួនតាមចំនួនដែលគ្រូថា ៗ

មេរៀនទី២. - ចំនួនដល់ ៣៩-

រៀនធ្វើលេខបូក ចំនួនដុំឥតត្រាទុក ៗ

របៀបបង្រៀន.-

១– ការហាត់គិតមាត់ទទេ ឲ្យសិស្សរាប់បង្កើនបន្ថែម បីៗ ពី ១ ដល់ ៣៩

២– ពន្យល់របៀបធ្វើលេខបូកនៅលើក្ដារខៀន

៣– ឲ្យសិស្សធ្វើលេខបូកនៅលើក្ដារខៀន

៤– ឲ្យសិស្សធ្វើលេខនៅលើក្ដារឆ្នួន

មេរៀនទី៣– ចំនួនពី ៤០ ដល់៤៩

ការរៀនរាប់ រៀនមើល រៀនសរសេរចំនួន ។

មេរៀនទី៤– ចំនួនដល់ ៤៩

រៀនធ្វើលេខសង់ចំនួនដុំឥត-គ្រាទុក ។
សូមធ្វើតាមរបៀបខាងលើ ។

## វង្វាស់វង្វាល់

អំពីរង្វាល់លីត្រ (ល)

របស់សំរាប់ប្រដៀង– លីត្រ ដីខ្សាច់ ប៉ោតទឹក

របៀបបង្រៀន –១– វិធីពិនិត្យស្គាល់

គ្រូលើករង្វាល់លីត្របង្ហាញសិស្ស សួរសាកឬប្រាប់សិស្សថា រង្វាល់នេះហៅលីត្រ ៗ គ្រូសរសេរ (លីត្រ) នៅលើក្ដារខៀន ហើយ សរសេរជាអក្សរកាត់ (ល) ១ល ៤ល ៧ល ៗ

គ្រូនាំសិស្សពិនិត្យប្រេកង់ទឹកពស់នៃលីត្រ ៗ

ឲ្យសិស្សម្នាក់វាល់ដីខ្សាច់ ១ ល, ចាក់ទៅលើក្ដារ ហើយនាំសិស្ស ពិនិត្យចំនួនដីខ្សាច់ ១ ល.នោះ ៗ ឲ្យសិស្សម្នាក់ទៀតវាល់ទឹក ១ ល. ចាក់ ទៅក្នុងកែវធំ ១ ហើយនាំសិស្សពិនិត្យចំនួនទឹក ១ ល. នោះ ៗ

២– វិធីហាត់ស្ទានចំណុះ

គ្រូចាក់ដីខ្សាច់១គំនរឲ្យសិស្សស្ទានៈហើយឲ្យសរសេរចំនួននៅលើ ក្ដារជូន ឲ្យសិស្សវាល់បញ្ជាក់ ៗ គ្រូចាក់ទឹកក្នុងធុង ១ ហើយឲ្យសិស្ស ស្ទានចំណុះទឹកនោះហើយវាល់បញ្ជាក់ ៗ គ្រូនាំសិស្សហាត់ស្ទានបែប ខាងលើនេះឲ្យបានច្រើន ៗ

៣– វិធីហាត់សរសេរ

សូមតែងជាចំណោទងាយ ៗ ពីរ ៗ តាមរបៀបលេខដែលសិស្សបាន

បេះហើយក្នុងការរៀនទន្ទួន ។ ឲ្យធ្វើនៅលើក្ដារខៀន នៅលើក្ដារឆ្មន នៅក្នុងសៀវភៅ

---

## អាទិកដ្ឋាន

## វត្ថុស្វាធ្យាយន៍

### អាទិត្យទី១- អំពីរុក្ខជាតិ

រុក្ខជាតិទាំងឡាយក៏មានជីវិតដែរ ប៉ុន្តែមិនអាចនឹងផ្លាស់ប្ដូរទីកន្លែង បានដោយងាយដូចជាសត្វទាំងពួងទេ ។

រុក្ខជាតិទាំងប៉ុន្មាន ដែលយើងពល់គ្នាឃើញនេះ គឺកើតមកតែអំ-ពីគ្រាប់ទាំងអស់ ឯគ្រាប់នោះគ្រាន់តែត្រូវខ្យល់ចំហាយថ្ងៃនិងទឹកក៏ចាប់បុសពន្លកដុះឡើង ។

ប្រយោជន៍នឹងឲ្យឃើញច្បាស់ដូច្នេះ យើងយកគ្រាប់សណ្ដែកពីរបីដាក់លើសំឡីសើមៗ ឬលើស្ពូសើមនៅក្នុងចានមួយដែលនៅកណ្ដាលពលចំហាយថ្ងៃល្មម លុះបន្តិចទៅគ្រាប់សណ្ដែកនោះក៏ចាប់បុសពន្លក

ឡើង ហើយឃើញចេញពីគ្រាប់មួយ ៗ កូនឈើតូចមួយមានឫសខ្ចីមាន ដើមតូចហើយមានស្លឹក ៗ

ចំណែកដើមឈើ - ដើមឈើមានឫស - ដើម និងស្លឹក)

ឫស- ឫសកែវ, ឫសយោងហើយនិងឫសឆ្មារ ដែលបែកចេញគ្រប់កន្លែង ឫសប្រយោជន៍អ្វី ? ( ភ្ជាប់ដើមឈើទៅនឹងដីហើយនិងស្រូបយកអា-ហារពីក្នុងដីមកចិញ្ចឹមជីវិតដើមឈើទាំងមូល )

ដើម– មានអ្វីខ្លះនៅលើដើម ? មានថ្នាំងមានពន្លកនិងស្លឹក ៗ ពន្លកនេះយូរបន្តិចទៅកើតជាមែក ៗ នៅលើមែកមានពន្លកផ្កា ៗ ផ្កាបង្កើតជាផ្លែ ៗ នៅក្នុងផ្លែមានសាច់និងគ្រាប់ ៗ

ដើម–ប្រយោជន៍អ្វី ? ទ្រមែកហើយនាំជាតិអាហារពីឫសមកស្លឹក ៗ ស្លឹករាងដូចម្ដេច ? ស្លឹកមានប៉ុន្មានចំណែក ? ស្លឹកភ្ជាប់ទៅនឹងមែកដោយសារអ្វី ? ស្លឹកប្រយោជន៍ដូចម្ដេចខ្លះ ? (ដើមឈើដកដង្ហើមនិងស្លឹកគឺស្លឹកនេះឯងហើយដែលផ្សំរសជាតិយកទៅចិញ្ចឹមគ្រប់កន្លែង ៗ

## អាទិត្យទី២– ១– អំពីការធ្វើស្រែ–២– អំពីរើសពូជ

វត្ថុសំរាប់បង្រៀន– គ្រាប់ស្រូវពូជល្អ - គ្រាប់ស្រូវពូជអាក្រក់ គួរស្រូវពូជផ្សេងៗពីគ្នា ៗ

ស្រូវពូជមានតែមួយបែបឬមានផ្សេងពីគ្នា ? ពូជបែបណាខ្លះ ? (បង្ហាញពូជស្រូវគ្រាប់វែង-គ្រាប់ខ្លី)ៗ ពូជនិមួយៗមានផលស្មើគ្នាឬមួយខុសពីគ្នា? បើចង់បានផលល្អ ត្រូវធ្វើដូចម្ដេច ? ត្រូវរើសរកពូជល្អតាមដែលបានផលល្អ ឯផលដែលឲ្យនេះខុសគ្នាមួយជាពីរជាបី) ។ រើសពូជយ៉ាងនេះជាការសំខាន់មួយ ប៉ុន្តែមិនមែនជាការស្រេចនោះទេ ។ ត្រូវសង្កេតមើលគួរស្រូវនៅក្នុងស្រែដោយហេតុអ្វីបានជាមានគួរខ្លះធំធាត់គួរខ្លះទៀតតូចក្រៀប (មកអំពីគ្រាប់ពូជអំពីដីជាតិដីទឹកទឹកមិនគ្រប់គ្រាន់ស្មើគ្នា ។

បើអ្នកស្រែមិនប្រយ័ត្នក្នុងរវាងពីរបីឆ្នាំ ស្រូវនោះក៏អន់ខ្សោយផល ។

ហេតុដូច្នេះត្រូវធ្វើដូចម្ដេចទើបស្រូវយើងចំរើន ។

## អាទិត្យទី ៣.- អំពីដី – ការបាកដី

គម្រមានអាហារណាដែលរុក្ខជាតិត្រូវការគ្រប់មុខក្នុងដី បំណែកមួយទៀតដីមានដីល្អត្រឡប់ទៅជាសោះអស់ ពីព្រោះដំណាំជញ្ជក់យកជាតិដីអស់ ។ ដូច្នេះត្រូវដាក់ដីដីឲ្យរឿយៗ ឯដាក់ដីឲ្យល្អត្រូវដាក់តែធាតុណាដែលដំណាំត្រូវការហើយមានកំរិតផង បើដាក់មិនត្រូវចំនួននោះនឹងនាំឲ្យខូចដំណាំទៅវិញដែរ ។ ដីខ្លះមានធាតុគ្រប់មុខគឺធាតុ "អាសូត" ក្បួនហើយនឹងអំបិលក្រោម ដីខ្លះជាដីបន្សំ (មានធាតុអស់នេះតែមួយមុខ) ។ ឯជីធម្មតាដូចជាលាមក សត្វពាហនៈ, លាមកមនុស្ស, សត្វដង្កូវនានា

ផេះ មុននឹងយកទៅដាក់ក្នុងដីមិនចាំបាច់យកទៅលាយទៀតទេ ។ ឯដីយើងធ្វើនោះត្រូវយកមកធ្វើឲ្យល្អជាមុន ទើបយកទៅដាក់ក្នុងដីដំណាំបាន) ។ មានដីមួយយ៉ាងទៀតហៅថាដីស្រស់ (ដូចជាដើមសណ្តែក-បាយ) ។

## អាទិត្យទី៤.– ការបាចទឹកបញ្ចូលស្រែ

ស្រែជាតិរស់ដោយសារទឹក ។ បើដីណាពុំសូវមានទឹក ត្រូវបាចទឹកដាក់ ។ នៅស្រុកខ្មែរគេបាចទឹកនឹងស្នាច កញ្ជើថាន ឬរហាត់ទឹក ។ ឯរហាត់ទឹកនេះគេមិនប្រើគ្រប់តែកន្លែងទេ គេច្រើនប្រើតែនៅទីណាដែលមានព្រែក មានទឹករើងមិនដាច់ក្នុងរដូវប្រាំង ដូចជាទីរួមខេត្តកណ្តាល តាកែវ ហើយនឹងសៀមរាប ឯអ្នកស្រុកទន្ទឹមនឹងទន្លេសាប គេប្រើចាំង ឬស្នាចធ្វើនឹងឈើឬស្សីខ្ទុកម្រក្សណ៍ដងទឹកស្រោចដំណាំ ។

---

អាទិកដ្ឋាន

## វិធីបង្ការរោគ

## អាទិត្យទី១និង ទី ២ អំពីរបៀបលាងនឹងរុំដំបៅ

វត្ថុសំរាប់ប្រើ៖— ទឹកក្តៅ - ទឹកត្រជាក់ - ថ្នាំ - សំឡី សំពត់រុំ

បើយើងមិនមើលដំបៅឲ្យស្រួល ដំបៅនឹងក្លាយឆាប់ណាស់ព្រោះមានមេរោគនឹងចូលមកប៉ះពាល់ ។ ហេតុដូច្នេះ ត្រូវរុំដំបៅនោះឲ្យជិត ។ មុននឹងរុំដំបៅ ឲ្យត្រូវសំអាតដៃនឹងសំឡីសំពត់រុំនោះ ទើបដំបៅនោះឆាប់ជា ។

ដើម្បីនឹងរុំដំបៅ គេត្រូវលាងនឹងទឹក «ប៉េម៉ង់កាណាត» ជាមុន គេយកសំឡីមួយដុំត្រាំក្នុងទឹកនោះ ហើយយកមកជូតដំបៅឲ្យជ្រះក្អែលក្រខ្វក់រួចគេគ្របមុខដំបៅនឹងកំណាត់សំពត់ រុំដំបៅដាក់សំឡីគ្របពីលើបន្តិចទើបគេយកសំពត់ស្អាតមករុំបង្វិលឲ្យជាប់មិនឲ្យរបូតបាន ។ បើមានហើមហើយឈឺទៀតនោះ គឺមកពីមានមេរោគមានខ្លះនៅឡើយ ត្រូវលាងទៀត ហើយរុំនឹងសំពត់ថ្មី ។

## អាទិត្យទី៣ នៃខែទី៤— សេចក្តីការពារខ្លួននឹងជម្ងឺឆ្លង

មើលក្នុងសៀវភៅវិធីបង្ការរោគសំរាប់កុមារដ្ឋាននឹងបរិវេណដ្ឋាន ទំព័រទី. ៣៤ ៣៥- ៣៦- ៣៧- ៣៨- ៣៩ នឹង ៤០ ។

## បរិច្ឆណាដ្ឋាន ៥

### វត្ថុស្វាធ្យាយន៍

អាទិត្យទី ១.– ១ កំណើតដើមឈើ

វត្ថុសំរាប់បង្រៀន គ្រាប់ស្វាយទុំ គ្រាប់ស្វាយពន្លកឫស គ្រាប់ស្វាយពន្លកចេញដើម កូនស្វាយយ៉ាងតូច បើយកដើមឈើអ្វីទៀតក៏បានដែរ ។

គ្រាប់ - គ្រូយកគ្រាប់ស្វាយបង្ហាញសិស្ស ពីខាងក្រៅគ្រាប់មានអ្វី ? ( សំបក ) ខាងក្នុងគ្រាប់មានអ្វី ? គ្រូបកគ្រាប់ឲ្យសិស្សមើល គឺមានសាច់នៅក្នុងគ្រាប់ មានពូជមួយដើមតូច បើគេយកកូនស្វាយនោះមកពិនិត្យមើល គេនឹងឃើញមានឫសមួយធ្នារ ។

ដើមមួយតូចហើយនឹងសន្ទូកត្រួយ កូនឈើនេះរស់ដោយអាហារដែលមាននៅក្នុងសាច់នៅក្នុងគ្រាប់ ។

កំណើតដើមឈើ បើគេយកគ្រាប់ស្វាយនេះទៅដាំឲ្យត្រូវខ្យល់ ទឹកនឹងថ្ងៃ តើគ្រាប់នេះបង្កើតបានជាអ្វី ? កាលបើត្រូវដីទឹកខ្យល់ កំដៅថ្ងៃហើយគ្រាប់នោះប្រេះឫសពន្លកចេញមក ហើយដុះចាក់ទៅក្នុងដី

ដើមក៏លូតឡើង សំបកបែកជាពីរ សន្ទឹកក៏ចេញមកលូតលាស់ធំឡើង កាលណាកូនឈើនោះលាស់ត្រង់ឡើងគ្រាប់ក៏ស្វិតហើយជ្រុះ កូនឈើនោះលូតលាស់ពេញទំហឹងហើយ ចិញ្ចឹមជីវិតដោយខ្លួនឯង ៗ

អាទិត្យទី ២.- ១ - អំពីស្រូវ

សូមគ្រូបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយថ្នាក់អាទិកដ្ឋាន

## ២ - អំពីពោត

អាទិត្យទី៣.- ១- អំពីដើមតែ ២- អំពីដើមគរ

អាទិត្យទី៤.- ១ - អំពីដើមដំបូង. ២- អំពីសណ្តែក

## ២- ដើមឈើ

វត្ថុសម្រាប់បង្រៀន- កូនឈើបីបួនដើមប្លែកៗពីគ្នា មែកឈើមានផ្កាមានផ្លែ ៗ

ចំណែកដើមឈើ- នាំសិស្សពិនិត្យមើលដើមឈើ ដើមឈើមានប៉ុន្មានចំណែក (ឫស-ដើម-ស្លឹក) ឫស ឫសកែវ ឫសយោងហើយសន្មាវដែលបែកចេញគ្រប់កន្ទង ឫសប្រយោជន៍អ្វី? ភ្ជាប់ដើមឈើទៅ

ទឹកដី ហើយទើបស្រូបយកអាហារពីក្នុងដីមកចិញ្ចឹមដើម ។

ដើម - មានអ្វីខ្លះនៅលើដើម? (មានថ្នាំងមានពន្លកស្លឹក ពន្លកនេះយូរបន្តិចទៅកើតជាមែក នៅលើមែកមានពន្លកផ្កា ផ្កាបង្កើតជាផ្លែ នៅក្នុងផ្លែមានគ្រាប់ ។

ដើមប្រយោជន៍អ្វី? ទ្រមែក ហើយនាំជាតិអាហារពីឫសមកស្លឹក ។

ស្លឹក - រាងដូចម្តេច? ស្លឹកមានប៉ុន្មានចំណែក ។

ស្លឹកភ្ជាប់ទៅនឹងមែកដោយសារអ្វី? ។

ស្លឹកប្រយោជន៍ដូចម្តេចខ្លះ? (ដើមឈើដកដង្ហើមនឹងស្លឹក គឺស្លឹកនេះឯង ហើយដែលផ្សំរសជាតិយកទៅចិញ្ចឹមគ្រប់កន្លែង) ។

---

បរិច្ឆណាដ្ឋាន

## វិធីបង្ការរោគ

### អំពីការសំអាត

សូមមើលក្នុងទស្សនាវដ្តីខែកញ្ញាមុននេះ បន្ទាប់មកពន្យល់សិស្សថា ការសំអាតខ្លួនសំលៀកបំពាក់នំ ចំណីអាហារ នោះមិនទាន់គ្រប់

គ្រាន់ទេ ត្រូវសំអាតផ្ទះសម្បែងទាំងកន្លែងអង្គុយ-ដេកផង ព្រោះខ្លួនអ្នកស្អាតហើយ ប៉ុន្តែអ្នកអង្គុយឬដេកលើកន្លែងមិនស្អាត អ្នកនឹងទទួលឆ្លងរោគពីគេដែរ ។

## ការសំអាតផ្ទះសម្បែង

ត្រូវបោសផ្ទះរាល់ថ្ងៃ មុនបោសត្រូវប្រោះទឹកក្តារឬឥដ្ឋក្រាល កុំឲ្យធូលីហុយទៅជាប់ជញ្ជាំងឬវត្ថុនា ៗ ។ ត្រូវយកសំពត់ជ្រលក់ទឹកសាប៊ូ ឬទឹកក្រេស៊ុលជូតតុកៅអីឲ្យសព្វកន្លែង មុងកំរាលពូកឬភួយត្រូវហាល-ថ្ងៃជារឿយ ៗ ហើយស្ងោរទឹកក្រេស៊ុលម្តង ៗ ផង ។

បើលោកគ្រូមានឱកាសទៅផ្ទះសិស្ស សូមពិនិត្យមើល តើសិស្សធ្វើតាមវិធីបង្ការរោគនេះឬទេ រួចពន្យល់ឪពុកម្តាយសិស្សនោះឲ្យចូលចិត្តនឹងសំអាតផ្ទះសម្បែងនេះផង ។

---

កុមារដ្ឋាន

## វត្ថុស្វាធ្យាយន៍

## អាធិត្យទី ១.— ១— អំពីគោ

វត្ថុសម្រាប់បង្រៀន.— ស្បែកគោដែលមានរោមជាប់ឆ្អឹងថ្គាម និងធ្មេញគោ រូបគោឈ្មោល គោញី កូនគោ ។

បង្ហាញស្បែកគោឲ្យសិស្សមើល ឲ្យស្ទាបរោមមានអ្វីដុសជុំវិញខ្លួនគោ ? សត្វអ្វីដែលមានរោមទៀតដូចគោ ? ឲ្យសិស្សពិនិត្យមើលជើងគោមានជើងប៉ុន្មាន ? នៅចុងជើងមានអ្វី ? ឲ្យធៀបក្រចកគោ និងក្រចកសេះ សត្វណាទៀតដែលមានជើងបួន ? ហើយក្រចកឥតឆែកដូចសេះ ឆែកដូចគោ ? ឲ្យសិស្សពិនិត្យមើលក្បាលគោ ហើយនិងធ្មេញគោ មានធ្មេញអ្វីខ្លះ ? ហេតុអ្វីបានជាគ្មានធ្មេញចង្កូម ?

ព្រោះបរិភោគតែស្មៅផុយ មិនត្រូវការខាំអ្វីដែលជារបស់ស្វិតរឹង ហេតុដូច្នេះធ្មេញចង្កូមក៏រួញបាត់ទៅ មានតែធ្មេញមុខនិងធ្មេញថ្គាមសម្រាប់ទំពាស្មៅ ។ អ្នកណាខ្លះបានសង្កេតមើលគោស៊ីស្មៅ វាស៊ីដូចម្ដេច ? វាទំពាអៀង គឺគ្រលៀសថ្គាមក្រោមពីឆ្វេងទៅស្ដាំ ពីស្ដាំទៅឆ្វេង ហើយកាលណាវាស៊ីស្មៅរួចហើយវាដេក ហើយក្អួតស្មៅដែលលេបទៅមុននោះយកមកទំពាម្ដងទៀត ឲ្យល្អិតទើបលេបទៅវិញ ។

សត្វដែលបរិភោគរបៀបគោនេះហៅថាសត្វទំពាអៀង សត្វណាខ្លះដែលទំពាអៀងដូចគោ ?

## ២– អំពីក្របី

សូមបង្រៀនតាមរបៀបមុន ។

អាទិត្យទី ២.- ១ អំពីសេះ = ២ អំពីឆ្កែ

នាំសិស្សពិនិត្យមើលធ្មេញចង្កូមឆ្កែវែងស្រួចហើយមាំ ព្រោះឆ្កែស៊ីសាច់ត្រូវការធ្មេញមុតសម្រាប់ខាំទំពា ឲ្យពិនិត្យមើលហើយនឹងក្រចកទៀត ក្រចកមុខខុបចុះក្រោម អាចទឹងដម្លើងឬទឹងសំរួមបានតាមត្រូវការ ឆ្កែជាសត្វដែលកើតឡើងមានប្រដាប់សម្រាប់ចាប់សត្វបរិភោគជាអាហារ សត្វឆ្កែកើតកូនយ៉ាងដូចម្ដេច ? ចិញ្ចឹមកូនយ៉ាងដូចម្ដេច ។ សត្វណាទៀតដែលមានចង្កូម ហើយនឹងក្រចកមុតដូចជាឆ្កែ ហើយបរិភោគសាច់ជាអាហារ (សត្វស្រុក- សត្វព្រៃ)

អាទិត្យទី ៣.- ១ អំពីជ្រូក

រកកូនជ្រូកមកទុកបង្រៀន បើគ្មានត្រូវឲ្យមានគំនូររូបជ្រូកឲ្យសិស្សពិនិត្យមើល ដូចរបៀបបង្រៀនអំពីឆ្កែនឹងគោខាងលើនេះ ។

២ អំពីមាន់

វត្ថុសម្រាប់បង្រៀន.– មេមាន់ ពងមាន់ រូបឆ្កែ ។ នាំសិស្ស

ពិនិត្យមើលក្បាលមាន់ ភ្នែកនឹងចំពុះ ចំពុះរឹងស្រួច សម្រាប់ចឹកអាហារ មានអ្វីផុសរំពុំផ្ទុំខ្លួន (មានពេមតូច) ពេមនោះប្រយោជន៍យ៉ាងដូចម្ដេច? (គ្របដណ្ដប់ខ្លួនការពារត្រជាក់) ។

នៅសងខាងខ្លួនមានអ្វី? (មានស្លាបពីរ) ស្លាបនោះប្រយោជន៍ដូចម្ដេច? មាន់មានជើងប៉ុន្មាន? ។ នៅចុងជើងមានអ្វី? ឲ្យសិស្សស្ទាបមើលខ្លួនមាន់ ហេតុដូចម្ដេចបានជាក្ដៅខ្លាំង? ព្រោះឈាមរត់ញាប់ មាន់កើតកូនដូចម្ដេច? ចិញ្ចឹមកូនដូចម្ដេច?

លក្ខណសត្វចតុប្បាទនឹងសត្វស្លាប ឲ្យសិស្សធៀបសត្វចតុប្បាទនឹងទ្វិបាទ ខុសគ្នាយ៉ាងណាខ្លះដូចឆ្កែនឹងមាន់ ។ល។

## អាទិត្យទី ៤.– ១ អំពីត្រី

វត្ថុសម្រាប់បង្រៀន .– ត្រីមានស្រកា ពងត្រី ទឹកមួយខ្ទាំ នាំសិស្ស ពិនិត្យខ្លួនត្រី ខ្លួនរាងដូចម្ដេច? (វែងធំកណ្ដាល ចុងដើមស្រួច ដើម្បីកុំឲ្យរាទឹក លើខ្លួនមានដុសអ្វី? ព្រុយដែលដុសនៅលើខ្នងឬក្រោមពោះត្រីហៅព្រុយអ្វី? ត្រីមានស្រកីប៉ុន្មាន? នៅត្រង់ណា? នាំសិស្សមើល ត្រីហែលព្រុយទ្រូងហើយនឹងព្រុយពោះប្រយោជន៍ដូចម្ដេច ។ (កកាយទឹកឲ្យត្រីលឿនទៅមុខ) ព្រុយកន្ទុយប្រយោជន៍ដូច

ម្តេច? (ប្រើជាចង្កូតសម្រាប់បត់ចុះបត់ឡើង) ព្រុយខ្នងនិងព្រុយឯទៀតសម្រាប់ទប់ទល់ត្រីឲ្យនៅបានក្នុងទឹក ហេតុដូចម្តេចបានជាស្រកីពណ៌ក្រហម? (ព្រោះមានឈាម) ត្រីដកដង្ហើមតាមស្រកីនេះឯង ត្រីទុកនៅលើគោករស់នៅបានឬទេ? យកពងត្រីឲ្យសិស្សពិនិត្យមើល ត្រីកើតកូនដូចម្តេច? ឲ្យសិស្សរាប់ឈ្មោះត្រីណាដែលស្គាល់ ៗ

---

## កុមារដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី ១.– ១– អំពីទឹកស្អុយ

វត្ថុសម្រាប់បង្រៀន.– ទឹកទន្លេឬបឹង ១ កែវ ទឹកម៉ាស៊ីន ១ កែវ ជំរង់ទឹកសាជូរ ៗ

យកទឹកទន្លេ ១ កែវទុកឲ្យរង់ហើយនាំសិស្សពិនិត្យមើលមានឃើញអ្វីខ្លះនៅក្នុងទឹក ? ទឹកទន្លេឬត្រពាំងថ្លុកនោះល្អក់ដោយមានកករជាតិដី ឥដ្ឋ - ខ្សាច់កំបោរ) ជាតិរុក្ខជាតិ (កំទេចស្លឹក - មែក - សំបក) ជាតិសត្វ (លាមក ពោម ឆ្អឹង) ជួនកាលមានពាំងមេរោគផ្សេងៗផង ទឹក

យ៉ាងនេះល្អផឹកឬទេ ? បើផឹកទៅៗបណ្ដាលជម្ងឺអ្វីខ្លះ ? (ឈឺពោះចុះមួល ឬរាកអ្វីផ្សេងៗទៅទៀត តាមមេរោគដែលមានក្នុងទឹកនោះ ធ្វើដូចម្ដេចទើបផឹកទៅឥតទោស បើចង់ឲ្យបានថាត្រូវក្បួនសាជួរ ឬមួយត្រង់នឹងដំរង (បង្ហាញដំរងសិស្ស) ប៉ុន្ដែធ្វើយ៉ាងនេះគ្រាន់តែបានថាប៉ុណ្ណោះទេ ឯមេរោគនៅតែមាន បើដូច្នេះធ្វើដូចម្ដេចទើបបានបរិសុទ្ធល្អ ត្រូវយកទៅដាំឲ្យពុះសម្លាប់មេរោគឲ្យអស់ចេញ ។

## ២– អំពីទឹកឆ្អិន

ធ្វើដូចម្ដេចឲ្យបានទឹកឆ្អិនសុទ្ធផឹកតាមត្រូវការ យើងយកថ្នាំប៉េរម៉ង់កាណាត មកលាយនឹងទឹកក៏បានដែរប៉ុន្ដែអ្នកស្រុកពុំធ្លាប់ប្រើតាមធម្មតា គេយកទឹកមកដាំឲ្យពុះចំនួន ១៥ មិនុត ទើបយកមកផឹកការទំលាប់ផឹកទឹកក្ដៅនេះនាំឲ្យយើងជៀសវាងជម្ងឺច្រើនប្រការ កាលណាស្រុកមានជម្ងឺ បើចង់ឲ្យទឹកក្ដៅនោះមានក្លិនរស់ល្អ ត្រូវធ្វើដូចម្ដេចទៀត ? យួនចិនប្រើទឹកតែជាប់ជាធម្មតា ខ្មែរយើងក៏ប្រើដែរ ខ្លះប្រើទឹកឬសដង្ហិតស្មៅ ឬឫសដូងព្រះ ទំលាប់យ៉ាងនេះជាការសំខាន់ ព្រោះកេសដ្ឋៈនេះមានគុណប្រយោជន៍ហើយថ្លៃតិចផង ។

អាទិត្យទី ៣.— អំពីផ្លែឈើ

ផ្លែឈើគេបរិភោគបានទាំងអស់ឬដូចម្តេច ? ចូរឲ្យដឹងថាផ្លែឈើខ្លះពុល (ស្លែងក្រចៅ) បើគេបានយកមកឲ្យសិស្សស្គាល់ ផ្លែឈើខ្លះទៀតមានជាតិជូរចត់ បរិភោគច្រើននឹងបណ្តាលឲ្យចុះរាក មិនត្រូវបរិភោគផ្លែឈើខ្ចី (ស្វាយត្របែក) ច្រើនហួសនោះទេ ព្រោះនាំឲ្យឈឺពោះម្យ៉ាងទៀតពេលណាមានកើតអាសន្នរោគ មិនត្រូវបរិភោគផ្លែឈើខ្ចីឬស្រស់ៗ

ផ្លែឈើដែលបរិភោគមានប្រយោជន៍ដល់ខ្លួននោះគឺ ចេក ក្រូច ល្ហុង ទៀបទុំ ៗ

អាទិត្យទី៤ .— អំពីបន្លែ

សូមបង្រៀនតាមរបៀបខាងលើនេះ ៗ

---

## លោកនីតិ

សម្រាប់គ្រប់ថ្នាក់

## សេចក្តីអធិប្បាយរដ្ឋធម្មនុញ្ញ

សេរីភាពសិទ្ធិនិងករណីយកិច្ចរបស់ខេមរជន

ដូចមានពោលមកហើយ បុគ្គលរាប់សែនរាប់លាននាក់រួមគ្នាតាំងឡើងជា

រដ្ឋ ៗ រដ្ឋបុរាជការ, មានអំណាចបង្គាប់បញ្ជាផ្ដន្ទាទោសលើបុគ្គលនិមួយៗ (បុរាស្ត្រ) ។ អំណាចនេះនាំជានិច្ចសម្បត្តិទ្រព្យរាងកាយរហូតដល់អាយុជីវិតនៃបុគ្គលនិមួយ ៗ ។ តាំងនេះគឺជាប្រយោជន៍ដល់បុគ្គលទាំងអស់គ្នាដូចជាការចាប់ចោរដាក់គុករឹបជាន់សម្បត្តិទ្រព្យប្រហារជីវិតមនុស្សក្បត់ជាតិជាដើម ។ តែរដ្ឋអាចប្រើអំណាចរំលោភលើបុគ្គលនិមួយ ៗ ដូចយើងធ្លាប់បានឃើញមកហើយ ។ ហេតុនេះទើបរដ្ឋធម្មនុញ្ញបញ្ញត្តកុំឲ្យរដ្ឋប្រើអំណាចជ្រុលហួសទៅលើបុគ្គលបាន ។

ក្នុងចំពូកនេះនិងក្នុងចំពូក ៣ ត្រង់មាត្រា ១៧ និង ១៨ មានស្ដីអំពីសេរីភាព (libesté) និងសមភាព (ègalité) របស់ខេមរជនគោលសេរីភាពនិងគោលសមភាព (Les principes delibeté et b'Egalité) ជាមូលដ្ឋាន (Base) នៃសិទ្ធិរបស់បុគ្គល (Doits indierduell) សិទ្ធិរបស់បុគ្គលនេះរដ្ឋមិនត្រូវរំលើសបានឡើយ ។

ក្នុងចំពូកនេះមានស្ដីអំពីករណីយកិច្ចរបស់ខេមរជនផង ព្រោះកាលមានសិទ្ធិក៏ត្រូវមានករណីយកិច្ចជាគូគ្នា ។

មាត្រា ៣.— សេរីភាពជាដំណើរអាចធ្វើបានគ្រប់យ៉ាងកុំឲ្យប៉ះពាល់ឲ្យខូចសិទ្ធិអ្នកដទៃ ។ លក្ខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុង

ច្បាប់ ៗ អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ ។

សេចក្ដីអធិប្បាយ.— មានសេរីភាពគឺធ្វើអ្វីបាន តែពុំមែនបានដរាបនោះទេ ត្រូវមានកំណត់ដែរ ៗ ឧបមាដូចជាខ្ញុំចង់ស្រែកច្រៀងខ្ញុំមានសេរីភាពស្រែកច្រៀងដូចម្ដេចក៏បាន ៗ ប៉ុន្តែបើដល់ពេលយប់ជ្រៅខ្ញុំស្រែកច្រៀងខ្លាំង ៗ ទៅអ្នកជិតខាងរកសំរាន្តពុំលក់ ។

អ្នកមានសិទ្ធិសំរាន្តពេលយប់ បើខ្ញុំច្រៀងមិនឲ្យអ្នកសំរាន្តបាននោះគឺខ្ញុំធ្វើឲ្យខូចសិទ្ធិរបស់អ្នកខាងការសំរាន្តសំរាកកាយ ៗ ក្នុងករណីដូច្នេះសេរីភាពរបស់ខ្ញុំអស់តែត្រឹមនេះ ។

នេះហើយជាព្រំដែននៃសេរីភាព ៗ " លក្ខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់ " ប្រែសេចក្ដីថាការប្រើសេរីភាពទៅដោយវិធីណាតាមបែបណា ខ្លះនោះមានបញ្ញត្តិទុកក្នុងច្បាប់ ៗ ដូចជាសេរីភាពខាងការធ្វើកាសែត,ដើម្បីនឹងប្រើសេរីភាពនេះបានត្រូវឲ្យមានអ្នកចាត់ការម្នាក់ជាអ្នកទទួលខុសត្រូវ; អ្នកចាត់ការនោះ ត្រូវធ្វើពាក្យទៅអ្នករាជការមុខក្រសួង ៗ ល ៗ នេះហើយហៅថាលក្ខណ្ឌនៃការប្រើសេរីភាពខាងការធ្វើកាសែត ៗ លក្ខណ្ឌទាំងនេះមានត្រាទុកក្នុងច្បាប់ ៗ បើច្បាប់នេះមិនទាន់មានក៏ត្រូវតាំងឲ្យមានឡើង ។

វគ្គទី ២ — នៃមាត្រា ៣ នេះបានសេចក្តីថា ៖ អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ សេចក្តីនេះក៏ក្បោះក្បាយល្មមស្តាប់បានហើយ តែដើម្បីឲ្យច្បាស់លាស់ឡើងទៀត គួរយើងរកឧទាហរណ៍មួយមកបញ្ជាក់ថែមផង ។ មនុស្សដែលដើរកាត់មុខវត្តអារាមខ្លះក៏បើកមួកខ្លះក៏មិនបើកមួក ការបើកមួកនៅមុខវត្តនេះគ្មានច្បាប់ណាបង្គាប់ឲ្យធ្វើទេគឺធ្វើដោយចិត្តឯង ។ ហេតុនេះនរណាទឹងបង្ខំនរណាឲ្យបើកមួកនៅមុខវត្តពុំបានឡើយ ។

មាត្រា ៤ — ទឹងចោទចាប់ឬឃុំឃាំងជនណាមួយបានលុះតែជននោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់, ឯអ្នកចោទអ្នកចាប់ឬអ្នកឃុំឃាំងត្រូវប្រតិបត្តតាមរបៀបដែលច្បាប់បានបញ្ញត្តិទុក ។

សេចក្តីនេះនាំឲ្យកើតឡើងជាបញ្ហា ៥ ប្រការ ៖

១) បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះដូចម្តេចខ្លះ ?

២) នរណាជាអ្នកចោទ ?

៣) នរណាមានអំណាចចាប់ ? ដើម្បីទឹងចាប់ត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះទើបត្រឹមត្រូវតាមច្បាប់ ?

៤) នរណាមានអំណាចឃុំឃាំង ? ដើម្បីទឹងឃុំឃាំងត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះទើបត្រឹមត្រូវតាមច្បាប់ ?

៥ ) នរណាចាប់ឃុំឃាំងខុសពីច្បាប់ត្រូវទទួលទោសយ៉ាងណាខ្លះ ? ។

យើងបានពិនិត្យច្បាប់ដែលមានប្រើសព្វថ្ងៃនេះ ហើយបានប្រឹក្សានឹងអ្នកថ្នឹកការក្នុងមុខក្រសួងតុលាការ ដោយចង់ដឹងថាច្បាប់ដែលមានប្រើសព្វថ្ងៃឲ្យសេចក្ដីឃុំគ្រងរក្សាដល់សេរីភាព ខាងរាងកាយនៃខេមរជនប៉ុណ្ណាទៅ ។ ទាំងនេះក៏ព្រោះយើងមានបំណងឲ្យបងប្អូនទាំងឡាយនេះប្រើបញ្ញត្តិច្បាប់ជាអាវុធការពារខ្លួន វៀរចាកការសង្កត់សង្កិនធ្វើបាបដើម្បីឲ្យបានគ្រងជីវិតដោយថ្ងៃថ្នូរសមល្មមនឹងឋានៈជាមនុស្សតទៅ ។

ដើម្បីឲ្យសាមញ្ញជនយល់បានដោយច្បាស់លាស់នោះ ត្រូវពន្យល់ដល់ខ្លួបល្អិតណាស់ ។

យើងនឹងពន្យល់ឲ្យល្អិតដល់ម៉្លោះក្នុងទីនេះពុំបានទេ ព្រោះនឹងនាំឲ្យសេចក្ដីអធិប្បាយវែងពេក ។ យើងនឹងព្យាយាមសង្ខេបយ៉ាងបំផុតតែក៏គង់នៅវែងដែរ ។

ប្រការ១– បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះដូចម្ដេចខ្លះ ? បទប្រព្រឹត្តទាំងនោះជាបទ ល្មើសដែលគេតែងចែកជាបីសណ្ឋានគឺបទឧក្រិដ្ឋ បទមជ្ឈិម នឹងបទលហុ ស្រេចតែទោសដែលត្រូវផ្ដន្ទាជាទោសឧក្រិដ្ឋ (ធ្ងន់ ) មជ្ឈឹម (កណ្ដាល) ឬលហុ (ស្រាល )

បទឧក្រិដ្ឋជាបទល្មើសដែលត្រូវផ្តន្ទាទោស ៖

បទឧក្រិដ្ឋប្រហារជីវិត (ថ្នាក់ទី៣)

បទឧក្រិដ្ឋដាក់គុក បង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត (ថ្នាក់ទី២ )

បទឧក្រិដ្ឋដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់វេលា (ថ្នាក់ទី១ )

(មាត្រា២១ក្រមព្រហ្មទណ្ឌ)

បទមជ្ឈិមជាបទល្មើសដែលត្រូវផ្តន្ទាទោស ៖

បទមជ្ឈិមដាក់គុកពី១ឆ្នាំទៅដល់ ៥ឆ្នាំ ហើយពិន័យពី១០០រៀល ទៅដល់ ១០០០រៀល (ថ្នាក់ទី៣ ) ។

បទមជ្ឈិមដាក់គុកពី ១ ខែទៅដល់ ១ ឆ្នាំនឹងពិន័យពី៣០រៀល ទៅដល់ ១០០ រៀល (ថ្នាក់ទី២) ។

បទមជ្ឈិមដាក់គុកពី ៦ ថ្ងៃទៅដល់ ១ ខែនឹងពិន័យពី ៦ រៀលទៅ ដល់៣០ រៀល (ថ្នាក់ទី១) ។

ទោសមជ្ឈិមទាំង៣ថ្នាក់នេះ គ្រាន់តែដាក់គុកឬគ្រាន់តែពិន័យក៏បាន (មាត្រា ២២. ក. ព)

បទលហុជាបទល្មើសដែលត្រូវផ្តន្ទាទោសដាក់គុកពី ១ ថ្ងៃទៅដល់៥ ថ្ងៃនឹងពិន័យពី ៤០ សេនទៅដល់ ៥ រៀល ឬគ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន (មាត្រា ២៣ ក ព) ។

បើជនណាមិនបានប្រព្រឹត្តបទល្មើសដែលមានត្រាទុកក្នុងច្បាប់នេះទេ គ្មាននរណាអាចចោទចាប់ឃុំឃាំងជននោះបានឡើយ ។ ជនណាចោទចាប់ ឃុំឃាំងមនុស្សដែលពុំបានប្រព្រឹត្តបទដែលមានត្រាទុកទុកក្នុងច្បាប់ជននោះល្មើសនឹងច្បាប់ហើយត្រូវទទួលទោសលើខ្លួនដូចនឹងមានពណ៌នាទៅខាងក្រោយនេះ ។

ប្រការ ២ នរណាជាអ្នកចោទ ?

តាមធម្មតាកាលមានបទល្មើសជាបទឧក្រិដ្ឋឬមជ្ឈិមបណ្ដាលកើតឡើង អ្នករងគ្រោះឬជនឯទៀតអាចប្ដឹងជាបទអាជ្ញាបាន ។ តែដែលនឹងចោទប្រកាន់ឲ្យប្រើអំណាចច្បាប់ដាក់ទណ្ឌកម្មនោះមានតែរដ្ឋមន្ត្រីក្រសួងយុត្តិ-ធម៌ឬអ្នកតំណាងរដ្ឋមន្ត្រីនេះទើបចោទបាន ។ ក្នុងជាន់ដំបូងអ្នកតំណាងនោះគឺព្រះរាជអាជ្ញា ។ ដូច្នេះក្នុងក្ដីអាជ្ញាអ្នកដើមចោទគឺព្រះរាជអាជ្ញាឬព្រះរាជអាជ្ញារងពុំមែនអ្នកដើមបណ្ដឹងទេ ។ ក្នុងសាលាដំបូងណាដែលគ្មានព្រះរាជអាជ្ញាចាងហ្វាងសាលាដំបូងនោះទទួលការជួស ។

(មាត្រា ៨ និង ៦៩ ក្រមពិភាក្សាព្រហ្មទណ្ឌ)

ពាក្យប្ដឹងក្នុងក្ដីអាជ្ញានឹងជូនផ្ទាល់ទៅព្រះរាជអាជ្ញាតែម្ដងក៏បាន នឹងជូនទៅនាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ណាមួយក៏បាន (offieur de

Police judiciaire) មាត្រា ៤៥ នឹង ៧៣ ក. ព. ព.) ឬនឹងជូនទៅរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ក៏បាន (មាត្រា ៨ ក. ព. ព. )

នាម៉ឺនដែលហៅថានាយក្នាក់ការក្រុមព្រះនគរបាលយុត្តិធម៌នោះគឺ

១)– ចៅហ្វាយខែត្រនឹងចៅហ្វាយស្រុក ,

២ ) មេឃុំឬជំទប់បើឥតពីមេឃុំ

៣) កុម្មិស្ស៊ែរ ប៉ូលិស

៤) នាយសន្ដរាម (officiers de gendarmerie) , មេកងសន្ដរាម (chef de brigade) នឹងសន្ដរាម, សេហ្សុស្តសន្ដរាម,

៥) មេព្រះនគរបាលសម្ងាត់នឹងភ្នាក់ងារដែលស្តីទីកុម្មិស្ស៊ែរប៉ូលិស ៗ

៦) សេហ្សុស្តរដ្ឋបាលនឹងសេហ្សុស្តប្រទល់ដែន

៧) ចៅហ្វាយក្រុមសាលាលហុ

៨) ព្រះរាជអាជ្ញា

៩) ស៊ុភាចាបុរស ៗ មាត្រា ៤០ ក. ព. ព. )

នាម៉ឺនណាបានទទួលបណ្ដឹង ហើយមិនបញ្ជូនទៅតុលាការមុខក្រសួង នាម៉ឺននោះគាប់ត្រូវទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៤ក .ព.) បើនាម៉ឺននោះបំបិទបំបាំង ឬមានចំណងនឹងបំបិទបំបាំងបទល្មើសទុក្រិដ្ឋ ឬមជ្ឈិមដែលខ្លួនបានដឹងហើយ ឬមួយបំបាត់ឬមានបំណងនឹងបំបាត់

ភ័ស្តុតាងបទល្មើសនោះ ព្រះរាជអាជ្ញាត្រូវចេញដីកាប្រាប់ទៅសាមីខ្លួនឲ្យដឹងផង (មាត្រា ៧៦ ក.ព.ព.) ។

សាមីខ្លួនអាចប្តឹងដល់សាលាក្រុមចោទ មួយលើកទៀតបាន (មាត្រា ៤៩៧ ក.ព.ព.) បើសាលាក្រុមចោទចេញសាលក្រម លើកពាក្យប្តឹងចោលទៀត សាមីខ្លួនអាចឧទ្ធរណ៍ទៅសាលាវិនិច្ឆ័យជាទីបំផុត (មាត្រា ៥០៦ ក.ព.ព.)

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្តីពាក្យប្តឹងនោះចូលទៅជាបទមជ្ឈិម ហើយក្នុងរឿងនោះពិបាករកសេចក្តីពិតក្តី អ្នកត្រូវចោទគេចខ្លួនបាត់ក្តី ឬមួយបើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្តីពាក្យប្តឹងនោះចូលជាបទឧក្រិដ្ឋនោះ ព្រះរាជអាជ្ញាធ្វើដីកាចាប់បញ្ជូនរឿងទៅសុភាចារបុរសឲ្យស៊ើបសួរ ។

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្តីពាក្យប្តឹងនោះចូលជាបទមជ្ឈិមហើយក្នុងរឿងនោះងាយរកសេចក្តីពិត នោះព្រះរាជអាជ្ញាអាចធ្វើដីកាកោះអ្នកត្រូវចោទឲ្យចូលខ្លួនមក ឲ្យសាលាមជ្ឈិមជំនុំជំរះតែម្តងក៏បាន ។ (មាត្រា ៧៧ - ៧៩ ក.ព.ព.) ។

រឿងក្តីអាជ្ញាច្បាប់ហាមមិនឲ្យនាម៉ឺនមុខក្រសួងផ្សះផ្សា ។ បើនាម៉ឺនមុខក្រសួងណាផ្សះផ្សាទាល់តែរឿងនោះរលាយបាត់ទៅ មិនមានប្តឹងដល់

តុលាការ នាម៉ឺនទោះអាចត្រូវទោសមធ្យមថ្នាក់ទី ២ (តាមមាត្រា ២៤៥ ក.ព.ព.) សេចក្ដីសង្កេត – របៀបចោទប្រកាន់ ដែលពោលមកខាងលើនេះ ប្រើបានតែកាលណាអ្នកប្រព្រឹត្តបទល្មើសជារាស្ត្រធម្មតា ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជានាម៉ឺន ត្រូវរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំអនុញ្ញាតពីគណៈរដ្ឋមន្ត្រីបានជាមុនសិន ទើបព្រះរាជអាជ្ញាចោទប្រកាន់បាន (មាត្រា ១១ ក.ព.ព.)

បើអ្នកប្រព្រឹត្តបទល្មើសជាមេឃុំ ត្រូវឲ្យបានអនុញ្ញាតពីចៅហ្វាយខេត្រជាមុនទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ដាក់ស្ដែង (មាត្រាដដែល) ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកតំណាងរាស្ត្រ ឬជាទីប្រឹក្សាព្រះរាជអាណាចក្រ ត្រូវបានអនុញ្ញាតពីរដ្ឋសភា ឬក្រុមប្រឹក្សាព្រះរាជអាណាចក្រជាមុនទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ដាក់ស្ដែង (មាត្រា ៥៩ និង ៧៧ នៃរដ្ឋធម្មនុញ្ញ) ។

បទល្មើសដែលរាប់ថាទាន់ដាក់ស្ដែងនោះ គឺបទល្មើសដែលកំពុងតែប្រព្រឹត្តរួចស្រាម ៗ ក្នុងមួយរំពេច ឬមួយអ្នកប្រព្រឹត្តបទល្មើសនោះ គេដេញតាមនៅឡើយ ពុំនោះសោតអ្នកប្រព្រឹត្តបទល្មើសនោះ គេបានទាន់ឃើញមានភស្តុតាងនៅខ្លួន ដូចជាសំលៀកបំពាក់អាវុធ គ្រឿងឧបករណ៍ ឬ

សំបុត្រស្នាម ដែលធ្វើឲ្យសំគាល់បានថាជាអ្នកប្រព្រឹត្តបទល្មើស ឬជាអ្នកសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសនោះមែន តែត្រូវឲ្យទាន់ឃើញក្នុងគ្រាដែលជិតបន្ទាប់ពីពេលប្រព្រឹត្តបទល្មើសនោះ (មាត្រា ៥៤ ក.ព.ព) ។

---

# មេសូត្រត់មាត់

## សម្រាប់គ្រប់ថ្នាក់

### ១– សេចក្ដីសប្បុរសនឹងមិត្តសំឡាញ់

នៃក្មេងប្រុសស្រី ចូរអ្នកមេត្រី ប្រណីដល់គ្នា
បើមានទាស់ខុស តិបត្តបក្ដីណា កុំមានទោសា
ប្រកាន់យកខុស ។ ព្រោះអ្នករាល់គ្នា រៀនក្នុងសាលា
ទាំងស្រីទាំងប្រុស រមែងភ្លាត់ភ្លាំង មិនដឹងខ្លួនខុស
ចូរអ្នកចាំចុះ មានខុសគ្រប់គ្នា ។ បើអ្នកចង់ល្អ
កាន់ចិត្តបវរ ប្រពៃថ្លៃថ្លា សំឡាញ់ទលក្រ
គាំទ្រគេក្រ ជួយយិតយោងគ្នា សិក្សាតទៅ ។

ពាក្យពន្យល់.–

មេត្រី= សេចក្ដីរាប់អាន ។ បវរ = (ម.ថ ប-វ៉ ) ប្រសើរ ។

## ២- សេចក្តីសុចរិតស្លូតត្រង់

សេចក្តីសុចរិត ស្លូតត្រង់ពិនិត្យ ជាពិតជាធម៌
ដែលពួកអ្នកប្រាជ្ញ លោកពោលថាល្អ ប្រកាន់ត ៗ
ទុកក្នុងសន្តាន ៗ ចុះសិស្សទាំងឡាយ នាំគ្នាខ្វល់ខ្វាយ
ប្រកាន់ឲ្យបាន ប្រកបសុចរិត ទឹងញាតិសន្តាន
ទាំងសិស្សដែលរៀន ក្នុងថ្នាក់ជាមួយ ៗ ព្រោះកម្មទុច្ចរិត
នាំឲ្យខូចចិត្ត បង្កើតទុក្ខព្រួយ គេស្អប់គេរៀរ
ចាកដើរជាមួយ ឥតមានគេស្ងួយ សរសើរឡើយហោង ៗ

## ៣- ការប្រុងប្រយ័ត្ន

សម្លៀកបំពាក់ ប្រដាប់នៃអ្នក ទុកដាក់ថែទាំ
សំអាតជានិច្ច ជាកិច្ចឧត្តម ទើបមិនបារម្ភ
ពីការខូចបង់ ៗ បើរៀនក្នុងថ្នាក់ ប្រុងស្តាប់ឲ្យជាក់
ចិត្តអ្នកតម្រង់ ចំពោះពាក្យគ្រូ ពន្យល់ផ្ចិតផ្ចង់
ធ្វើកាយឲ្យត្រង់ កុំផ្អាកធ្វេងស្តាំ ៗ ឯករណីយកិច្ច
ខំធ្វើឲ្យស្រេច កុំឲ្យសាំញ៉ាំ ខំធ្វើឲ្យល្អ
កុំឲ្យឆ្គងឆ្គាំ មេរៀនត្រូវចាំ ស្វាធ្យាយឲ្យចាំ ៗ

ពាក្យពន្យល់-

ធារម្ភ= (ម.ថ. ធារម៉្ភ ) នឹកព្រួយ ។ ករណីយកិច្ច= (ម.ថ. ក:-រ:-ណីយ:កិច្ច ) កិច្ចដែលត្រូវធ្វើ ។

### ៤- ប្រហែសធាត់-ប្រយ័ត្នគង់

នៃសិស្សអ្នកសិក្សា ចូរការពារប្រដាប់អ្នក
ថែទាំជួសទុកដាក់ នោះទើបអ្នកបានប្រើយូរ ។
ព្រោះអ្នកធ្វើការក្តី តាំងស្មារតីខំគិតគូរ
ទើបកិច្ចអ្នកថៃថ្នូរ កុំបន្ធូរប្រហែសឡើយ ។
ប្រហែសនាំឲ្យបាត់ ប្រហែសធាត់ជាទុក្ខហើយ
ទោមនស្សឥតមានស្បើយ នៃអ្នកអើយចាំប្រត្យក្ស ។
ចាំបង់ផុងគំនិត ចាំឲ្យពិតកង់អត្ត:
អ្នកប្រាជ្ញពោលថាអ្នក បវរ:ប្រសើរហោង ។

ពាក្យពន្យល់-

ទោមនស្ស= (ម.ថ. ទោម:ន័ស) សេចក្តីតូចចិត្ត; សេចក្តីអាក់អន់ចិត្ត ។ ប្រត្យក្ស= (ម.ថ. ប្រត្យ័ក) ប្រាកដ,ច្បាស់, មែន ។ អត្ត:= (ម.ថ. អ័ត-ត: ) ខ្លួន ។ បវរ: = (ម.ថ. ប:-វ:-រ-) ប្រសើរ ។

## ៩- សេចក្ដីផ្ចិតផ្ចង់

កិច្ចការងារទាំងអស់ សិស្សស្រីប្រុសត្រូវផ្ចិតផ្ចង់
តម្រូវឲ្យត្រូវត្រង់ កុំឲ្យលង់ជ្រុលខុសបាន ។
ករណីយកិច្ចគេ មុនសរសេរឬមុនអាន
គិតហើយទើបគេបាន និយាយអានសរសេរក្រោយ ។
កិច្ចអ្វីផងណា ប្រាសពិចារណ៍ពិនិត្យហើយ
កិច្ចនោះពុំល្អឡើយ មុខជាខុសក្លាំងក្លាត់បាន ។
ដូច្នេះសិស្សទាំងឡាយ កុំគិតងាយក្នុងសន្ដាន
កិច្ចអ្វីអ្នកត្រូវអាន ឬសរសេរគិតជាមុន ។

ពាក្យពន្យល់ -

ករណីយកិច្ច = (ម.ថ. ក: -រ: -ណី -យ: កិច្ច) កិច្ចដែលត្រូវធ្វើ ។

ពិចារណ៍ ( ម.ថ. ពិ-ចា ) ពិចារណា

រោងពុម្ពខ្មែរ